MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 1

CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៤ ថ្ងៃទី០១-៣០ ខែវិច្ឆិកា ឆ្នាំ២០១០ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៣៩

មាតិកា



អ្នកជំនាញលើកទឹកចិត្តឱ្យយុវជនអភិរក្សវប្បធម៌ ទំព័រ ៥



រៀនវិទ្យាសាស្ត្រផ្តល់ការងាយស្រួលរកអាហារូបករណ៍ ទំព័រ ៩



បូជនីយចរណ៍លើកដំបូង... ទំព័រ ១៤

# ភាពក្រីក្រគឺជាឧបសគ្គចម្បងក្នុងការជំរុញផែនការអប់រំដើម្បីទាំងអស់គ្នា



ប្រទេសជាតិអាចនឹងរីកចម្រើនទៅថ្ងៃអនាគត ដោយសារប្រជាពលរដ្ឋគ្រប់រូបមានចំណេះដឹង។ ប៉ុន្តែភាពអសកម្មមួយចំនួននៅក្នុងសង្គមនៅតែជាឧបសគ្គធំសម្រាប់ផែនការអប់រំដើម្បីទាំងអស់គ្នានេះ ដូចជា ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធសិក្សាធិការ កង្វះធនធានមនុស្ស និងកង្វះគុណភាពអប់រំជាដើម។ ទំព័រទី១០_១១

កម្មវិធី **ពន្លកថ្មី** ជាកម្មវិធីវិទ្យុថ្មីមួយរបស់
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក។
កម្មវិធីនេះផ្តោតលើពលកម្មកុមារ និងបញ្ហាការកេងប្រវ័ញ្ច
លើកុមារ មានផ្សាយនៅរាល់ ថ្ងៃច័ន្ទ ម៉ោង ៤-៥ រសៀល
នៅវិទ្យុសម្លេងប្រជាធិបតេយ្យ VOD, FM 106.5 MHz ។




**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 102.5 Mhz ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ



Photo : S. Philong

លោកបាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិបានមកធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជាថ្ងៃទី២៨ ខែតុលា និងបានពិភាក្សាបញ្ហាជាតិសំខាន់ៗជាមួយថ្នាក់ដឹកនាំកម្ពុជា។



Photo : S. Philong

លោកស្រីហ៊ីឡារី គ្លីនតុន ប្រមុខការទូតអាមេរិកបានមកធ្វើទស្សនកិច្ចជាផ្លូវការនៅកម្ពុជាកាលពីថ្ងៃទី៣១ តុលា និងបានពិភាក្សាបញ្ហាផ្សេងៗ ជាមួយនាយករដ្ឋមន្ត្រីកម្ពុជា ដូចជាបញ្ហាបំណុលកម្ពុជាជំពាក់ និងសិទ្ធិមនុស្ស។



Photo : S. Philong

ប្រឡាយលូទឹកស្អុយចំហមួយ ទឹកបែកពពុះនៅពេលភ្លៀងធំ ដែលធ្វើឱ្យ ជះក្លិនមិនល្អ នៅសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ។



Photo : S. Philong

កង្វះខាតទឹកស្អាតប្រើប្រាស់នៅតែជាមូលហេតុចម្បងនៃជំងឺនានាដែលប៉ះពាល់ដល់សុខភាពប្រជាជន និងការអភិវឌ្ឍនៅតាមតំបន់ជនបទ។



Photo : S. Philong

កុមារនៅតាមជនបទធ្វើការនេសាទដើម្បីស្វែងរកម្ហូបអាហារដើម្បីឧបត្ថម្ភគ្រួសារជំនួសឱ្យការទៅរៀនស្វែងរកចំណេះដឹងដើម្បីអនាគត។

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 3



# ផ្តល់ឱកាសសិក្សាដល់កុមារ គឺផ្តល់មត៌កដ៏មានតម្លៃ !



លោកលី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

ការអប់រំបណ្តុះបណ្តាលធនធានមនុស្ស គឺសំខាន់ចាំបាច់សម្រាប់ការអភិវឌ្ឍជាតិ។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកែទម្រង់ និងលើកកម្ពស់វិស័យអប់រំសម្រាប់ពលរដ្ឋរបស់ខ្លួនដែរ ដោយបានដាក់នូវប្រធានបទ "អប់រំដើម្បីទាំងអស់គ្នា"។

បើនិយាយពីវិស័យអប់រំនៅកម្ពុជា មានមតិជាច្រើនយល់ឃើញខុសៗគ្នា។ ខ្លះថា ការអប់រំនៅកម្ពុជា នៅមានកម្រិត ដោយបន្ទោសរដ្ឋាភិបាលថា ធ្វើកំណែទម្រង់យឺតយ៉ាវ។ តាមសេចក្តីពិត រដ្ឋាភិបាលក៏បានខំប្រឹងយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋទាំងអស់ ឱ្យនាំកូនដែលគ្រប់អាយុ ទៅចុះឈ្មោះចូលរៀន។ រាជរដ្ឋាភិបាលបានជំរុញឱ្យពលរដ្ឋទាំងទទួលយកនូវការអប់រំ យ៉ាងទាបត្រឹមថ្នាក់ទី៩ (មធ្យមសិក្សា)។ សាលារៀនជាច្រើនពាន់ខ្នងបានសាងឡើងនៅជិតផ្ទះប្រជាពលរដ្ឋ។ កុមារដែលមានអាយុអាចចុះឈ្មោះចូលរៀននៅឆ្នាំ២០១០ មាន ២លាននាក់ ហើយចុះឈ្មោះបានពី ៩៥% ទៅ៩៦%។ ប៉ុន្តែអត្រាសិស្សបោះបង់ការ សិក្សាឆ្នាំ២០០៩-២០១០ ក៏មានចំនួនគួរឱ្យព្រួយបារម្ភផងដែរ គឺមានចំនួន ៨,៥%។

ចំពោះកម្រិតការសិក្សា កុមារជាច្រើនដែលបានរៀនដល់ថ្នាក់ទី៥ និងទី៦ មិនទាន់ចេះអានច្បាស់លាស់។ នេះមិនមែនជាកំហុសទាំងស្រុងលើស្ថាប័នអប់រំរបស់រដ្ឋនោះទេ គឺត្រូវការចូលរួមយកចិត្តទុកដាក់របស់អាណាព្យាបាលឪពុកម្តាយជួយជំរុញកូនឱ្យមានទម្លាប់ក្នុងការអាន និងសរសេរ ពីព្រោះយើងទាំងអស់គ្នា ក៏ដើម្បីការអប់រំ។ យើងត្រូវចូលរួមទាំងអស់គ្នា។ ចំពោះអ្នកនៅជិតកុមារក៏គួរធ្វើគំរូសម្រាប់កុមារឱ្យមានទម្លាប់ក្នុងការរៀនសូត្រ។

បើយើងលើកយកគ្នាជីវភាពមកនិយាយនោះគឺត្រូវ ប៉ុន្តែមិនមែនកុមារជាអ្នកទទួលបន្ទុកលើបញ្ហានេះ។ នេះជាតួនាទីរបស់ឪពុកម្តាយ និងអាណាព្យាបាលដែលទទួលខុសត្រូវ ទាំងស្រុងក្នុងការបីបាច់ថែរក្សា និងផ្តល់ការអប់រំសម្រាប់កុមារ។

## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ាន្វអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែវិច្ឆិកា

-អាទិត្យទី៣២ ក្នុងរដូវធម្មតា ថ្ងៃអាទិត្យទី០៧ ខែវិច្ឆិកា ឆ្នាំ២០១០ ៖ ចូលរួមដោយបងប្រុសផាន ឫរី និស្សិត ទេវវិទ្យាល័យ។

-អាទិត្យទី៣៣ ក្នុងរដូវធម្មតា ថ្ងៃអាទិត្យទី១៤ ខែវិច្ឆិកា ឆ្នាំ២០១០ ៖ ចូលរួមដោយបងស្រីកល្យាណ មកពីព្រះ សហគមន៍កំពង់ធំ។

-អាទិត្យបុណ្យលើកតម្កើងព្រះគ្រីស្តជាព្រះមហាក្សត្រនៃពិភពលោក ថ្ងៃអាទិត្យទី២១ ខែវិច្ឆិកា ឆ្នាំ២០១០ ៖ ចូលរួមដោយលោកអភិបាលអេមីល ដេតម្ប។

-អាទិត្យទី១ ក្នុងរដូវរង់ចាំ ថ្ងៃអាទិត្យទី២៨ ខែវិច្ឆិកា ឆ្នាំ២០១០ ៖ ចូលរួមដោយលោកបូជាចារ្យវ៉ាំងសង់ សេនីយ៍សាល់នៃព្រះសហគមន៍កាតូលិកសន្តយ៉ូសែប។

### "ខ្ញុំត្រូវការអ្នក" ខែវិច្ឆិកា (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០៨ វិច្ឆិកា ៖ យុវជន និងការងារនៅ ប្រទេសម៉ាឡេស៊ី។ ថ្ងៃទី០៩ វិច្ឆិកា ៖ យុវជន និងចំណាប់អារម្មណ៍ថ្ងៃឯករាជ្យ។ ថ្ងៃ ទី១៥ វិច្ឆិកា ៖ យុវជន និងវគ្គបណ្តុះបណ្តាលនានា។ ថ្ងៃទី១៦ វិច្ឆិកា ៖ ទីផ្សារការងារយុវជន។ ថ្ងៃទី២២ វិច្ឆិកា ៖ យុវជនក្នុងឱកាសបុណ្យអុំទូក។ ថ្ងៃទី២៣ វិច្ឆិកា ៖ ចាក់ផ្សាយឡើងវិញប្រធានបទថ្ងៃទី២២ វិច្ឆិកា ដោយមានធុរៈរវល់ប្រជុំក្រុមវិទ្យុ វ៉ារីតាស។ ថ្ងៃទី២៩ វិច្ឆិកា ៖ យុវជន និងភាពជោគជ័យ។ ថៃទី៣០ វិច្ឆិកា " យុវជន និងការងារសហគមន៍។ សូមបញ្ជាក់ថា ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់។ **សូមកុំភ្លេចតាមដាន!**

**ការិយាល័យព័ត៌មានកាតូលិក**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង វីរជ័យ។ ប្រធាន : លោកលី សុវណ្ណា។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 4

# សេដ្ឋកិច្ច

## កម្ពុជាទទួល ១,៥លានដុល្លារ លើទីផ្សារផ្ដៅពិភពលោក តម្លៃ ៤ពាន់លាន ដុល្លារ

**ខាន់ ភិរម្យ**

ប្រធានគម្រោងផ្ដៅរបស់អង្គការមូលនិធិសត្វព្រៃពិភពលោក បានឱ្យដឹងថា នៅលើពិភពលោក ទំនិញកែច្នៃពីផ្ដៅមានតម្លៃប្រមាណ ៤ពាន់លាន-ដុល្លារ តែសម្រាប់កម្ពុជាវិញទាក់ទាញបានត្រឹមតែ ១,៥លាន ដុល្លារតែប៉ុណ្ណោះ។


Photo : S. Philong

លោកអ៊ូ រតនៈ ជាប្រធានគម្រោងផ្ដៅបានមានប្រសាសន៍ថា មូលហេតុដែលកម្ពុជានៅពុំទាន់អាចទាញយកប្រយោជន៍បានដ៏ច្រើនពីផលិតផលផ្ដៅ ដោយសារផលិតផលផ្ដៅនៅក្នុងប្រទេសនៅមិនទាន់រកបានទីផ្សារនៅក្រៅប្រទេសនៅឡើយ ។

យោងតាមប្រសាសន៍របស់លោករតនៈ ផ្ដៅនៅប្រទេសកម្ពុជា ត្រូវបានគេរកឃើញមានរហូតដល់ទៅ២១ប្រភេទ។ ប៉ុន្តែប្រភេទដែលមានតម្លៃផ្នែកសេដ្ឋកិច្ចនោះ មានប្រមាណ ៥ប្រភេទ ប៉ុណ្ណោះ។

លោកលិប ជាង ប្រធានសមាគមកែច្នៃផលិតផលផ្ដៅកម្ពុជា មានប្រសាសន៍ថា ទីផ្សារឧស្សាហ-កម្មកែច្នៃគ្រឿងសង្ហារិមផ្ដៅមានតម្លៃមហាសាលនៅលើទីផ្សារអន្តរជាតិ តែការនាំចេញរបស់យើងនៅមានការលំបាកច្រើនណាស់។

តាមផែនការរបស់សមាគម កម្ពុជាក៏គ្រោងនឹងនាំចេញគ្រឿងសង្ហារិមដែលកែច្នៃពីផ្ដៅទៅទីផ្សារអន្តរជាតិឱ្យបានក្នុងឆ្នាំ២០១១។ តែបើតាមលោកលិបជាង ការនាំចេញមានបញ្ហាប្រឈមច្រើន ។

លោកលិប ជាង អះអាងថា កាលណាបើកទី-ផ្សារ យើងត្រូវគិតដល់ការប្រកួតប្រជែងពីតម្លៃ។ ចំពោះតម្លៃ យើងនៅថ្លៃជាងគេដោយសារវត្ថុធាតុដើមភាគច្រើននៅឆ្ងាយពីទីក្រុងភ្នំពេញ ដែលទាមទារការដឹកជញ្ជូន។ ប៉ុន្តែតម្លៃដឹកជញ្ជូនយើងថ្លៃ។ ដូច្នេះវត្ថុធាតុដើមភាគច្រើនក៏ហូរចេញទៅក្រៅ។ លោកក៏បានឱ្យដឹងទៀតថា ជាទូទៅ រហូតមកដល់ពេលនេះ ផ្ដៅដែលជាវត្ថុធាតុដើមដ៏ចម្បងសម្រាប់ការកែច្នៃនោះ ត្រូវបានប្រជាជនប្រមូលលក់ទៅឱ្យប្រទេសជិតខាង។ នៅតាមបណ្ដាខេត្តជាប់ព្រំដែនវៀតណាម គេដឹកទៅលក់នៅវៀតណាម។ ខេត្តជាប់ព្រំដែនថៃ គេដឹកទៅលក់ថៃ។ ចំណែកយើងនៅកណ្ដាលពិបាករឿងវត្ថុធាតុដើម។ លោកក៏បានបញ្ជាក់ថា ទាំងនេះសុទ្ធតែជាបញ្ហាប្រឈមរបស់យើង ដែលជាផលិតករ នៅពេលដែលបើកទីផ្សារអន្តរជាតិនៅពេលខាងមុខ។ ម្យ៉ាងវិញទៀត មកដល់សព្វថ្ងៃនេះ យើងក៏មិនទាន់ដឹងថា តើផ្ដៅដែលដុះនៅក្នុងស្រុកខ្មែរយើងនេះ មានបរិមាណប៉ុន្មានច្បាស់លាស់នៅឡើយទេ។

### អ្នកនាំចេញផលិតផលផ្ដៅធំជាងគេ គឺ ឥណ្ឌូនេស៊ី

លោកលិប ជាង ប្រធានសមាគមផ្ដៅកម្ពុជា មានប្រសាសន៍ថា សព្វថ្ងៃនេះ ផលិតករនាំចេញផ្ដៅដែលកាន់កាប់ទីផ្សារអន្តរជាតិធំជាងគេ គឺប្រទេសឥណ្ឌូនេស៊ី។

លោកបន្ថែមថា ហ្វីលីពីន និងម៉ាឡេស៊ីក៏ជាប្រទេសចម្បងៗ នាំចេញផលិតផលផ្ដៅផងដែរ ក្រៅពីនេះមានវៀតណាម និងថៃជាដើម។ លោកញ្ជាក់ថា: "ប្រទេសជិតខាងមានប្រើប្រាស់វត្ថុធាតុដើមខ្លះពីស្រុកយើង។ រីឯថ្វីដៃកែច្នៃគឺប្រហាក់ប្រហែលគ្នា"។ លោកបន្តថា សម្រាប់ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងម៉ាឡេស៊ី យើងអត់អាចប្រកួតប្រជែងបានទេ ដោយសារគុណភាពផ្ដៅនៅប្រទេសទាំងនេះល្អ តែសម្រាប់ប្រទេសវៀតណាម ថៃ និងឡាវ យើងអាចប្រកួតប្រជែង បានទាំងគុណភាព វត្ថុធាតុដើម និងថ្វីដៃកែច្នៃ។

# សុខភាព

## គ្រូពេទ្យឯកទេស : "ការគិតតែរឿងអវិជ្ជមានច្រើននាំដល់ជំងឺធ្លាក់ទឹកចិត្ត"

**ជាត សំភី**

យោងតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត មុនី សុត្ថារា ការធ្លាក់ទឹកចិត្តគឺជាជំងឺផ្លូវចិត្តម្យ៉ាងដែលធ្វើឱ្យចិត្តរបស់យើងធ្លាក់។

លោកវេជ្ជបណ្ឌិត មានប្រសាសន៍ថា ជំងឺនេះធ្វើឱ្យប៉ះពាល់ទាំងផ្លូវអារមណ៏ និងរាយកាយ។ ខាងផ្លូវអារម្មណ៏ ទឹកចិត្តរបស់អ្នកជំងឺមានការធ្លាក់ចុះជាចម្បង។ អ្នកជំងឺអស់សង្ឃឹម។ គាត់គិតថា ខ្លួនគាត់មានតម្លៃនិងពុំមាននរណាជួយគាត់។ ចំណែកខាងផ្លូវកាយ រាយកាយអ្នកជំងឺទន់ខ្សោយ ដោយសារគាត់ហូបមិនបាន គេងមិនលក់សូមបីអារម្មណ៏ផ្លូវភេទ របស់គាត់ក៏អស់ដែរ។


Photo : V. Sambath

លោកវេជ្ជបណ្ឌិតមុនី សុត្ថារាបន្តថាតាមធម្មតាពេលមនុស្សជួបនូវវិបត្តិ គាត់ខិតខំដោះស្រាយដោយខ្លួនឯង ឬក៏ខំប្រឹងសម្របសម្រួលខ្លួនទៅនឹងវិបត្តិទាំងនោះ។ ប៉ុន្តែនៅពេលការខិតខំប្រឹងតទល់ឬសម្របសម្រួលជាមួយវិបត្តិទាំងអស់នោះ បរា-ជ័យជាបន្តបន្ទាប់។ គាត់ក៏មានស្រ្តេស៏ខ្លាំង និងគិតតែរឿងអវិជ្ជមាន នាំគាត់មានវិបត្តិធ្លាក់ទឹកចិត្ត។

លោកវេជ្ជបណ្ឌិតឯកទេស ក៏បន្ថែមថា ផលប៉ះពាល់នៃជំងឺធ្លាក់ទឹកចិត្ត គឺមានទាំងនៅលើខ្លួនអ្នកជំងឺផ្ទាល់និងគ្រួសារដែរ។ អ្នកជំងឺធ្លាក់ទឹកចិត្ត មិនអាចមើលថែទាំខ្លួនឯង និងពុំអាចធ្វើការងារបាន។ ពេលខ្លះ គាត់មិនសិតសក់ គេងមិនលក់ ហូបមិនបាន ឬគេងមិនលក់។ ក្នុងករណីធ្ងន់ធ្ងរ គឺគាត់អាចសម្លាប់ខ្លួន។ សម្រាប់គ្រួសារ នៅពេលអ្នកជំងឺធ្វើការមិនកើតនោះ នឹងបាត់បង់អ្នករកចំណូល។

លោកមុនី សុត្ថារា ផ្ដល់អនុសាសន៏ថា នៅពេលបុគ្គលម្នាក់មានជំងឺផ្លូវចិត្ត។ សមាជិកគ្រួសាររបស់គាត់គួរតែផ្ដល់ការគាំទ្រខាងផ្លូវចិត្ត ជួយពិភាក្សាពិគ្រោះយោបល់ ឬក៏ជំរុញឱ្យគាត់ទៅរកគ្រូពេទ្យឯកទេសដើម្បីទទួលការព្យាបាល។

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 5





Photo : S. Philong

# អ្នកជំនាញលើកទឹកចិត្តឱ្យយុវជនអភិរក្សសិល្បៈវប្បធម៌ជាតិ

**ខាន់ ភីរម្យ**

ដោយសារតែសកលភាវូបនីយកម្ម ការហូរចូលនូវវប្បធម៌បរទេសមកក្នុងប្រទេស គឺជារឿងដែលមិនអាចទប់ស្កាត់បាន។ ប៉ុន្តែការអភិរក្សនូវសិល្បៈវប្បធម៌ជាតិ គឺជារឿងដែលយុវជនគ្រប់ៗរូប ត្រូវនាំគ្នាគិតពិចារណា។ នេះបើតាមប្រសាសន៍របស់អ្នកជំនាញដែលធ្វើការជាមួយយុវជនមួយរូប។

កញ្ញាម៉ៅ ពុទ្ធារ័ត្ន អ្នកសម្របសម្រួលនៃក្រុមប្រឹក្សាយុវជនកម្ពុជា មានប្រសាសន៍ថា ដោយសារតែចរន្តនៃសកលភាវូបនីយកម្ម កម្ពុជាកំពុងទទួលយកនូវការហូរចូលវប្បធម៌បរទេសពីគ្រប់ទិសទី។ យុវជនកម្ពុជាមួយចំនួន ដែលពិចារណាពុំទាន់គ្រប់ជ្រុងជ្រោយ ប្រឈមមុខនឹងបញ្ហាមួយចំនួន ដូចជាគេភ្លេចការសិក្សា ភ្លើតភ្លើន ឬសម្ភារៈនិយម ដែលទង្វើទាំងនេះ អាចនឹងជះឥទ្ធិពលជាអវិជ្ជមានដល់ជីវិត និងអនាគតរបស់ពួកគេ។ កញ្ញាបញ្ជាក់ថា៖ "ពេលទៅសាលារៀន ការផាត់ម្សៅ ការធ្វើក្រចក ការស្លៀកពាក់ខ្លីៗ មិនមែនជាទម្លាប់ ដែលយុវជនសម័យមុនៗ គេធ្វើច្រើនទេ។ តែឥឡូវនេះសកម្មភាពទាំងនេះហាក់ដូចជាមានច្រើន"។

សាស្ត្រាចារ្យមួយរូប ដែលសុំមិនបញ្ចេញអត្តសញ្ញាណ មានប្រសាសន៍ថា សិស្សសាលាឥឡូវ គេទំនើប និងហ៊ឺហាណាស់។ អ្នកខ្លះមិនត្រឹមតែស្លៀកពាក់ខ្លី អាវស្តើង និងលាបម្សៅទេ។ ជួនកាលពួកគេមានរហូតដល់ទូរស័ព្ទទាក់ទងគ្នា និងថើបគ្នានៅក្នុងថ្នាក់ផងដែរ។ លោកបញ្ជាក់ទៀតថា៖ "សិស្សឥឡូវនេះ គេដូចជាលែងសូវនិយាយអំពីរឿងរៀនទេ ឱ្យតែជួបគ្នា ប្រធានបទរបស់គេ គឺមានតែរឿងចម្រៀង ឡេម្សៅ ទូរស័ព្ទ ឬសម្លៀកបំពាក់..."។

ជុំវិញបញ្ហានេះ អ្នកសម្របក្រុមប្រឹក្សាយុវជនខាងលើ ប្រាប់ឱ្យដឹងថា យុវជនសម័យបច្ចុប្បន្ននេះហាក់ដូចជាមានការចាប់អារម្មណ៍លើបញ្ហាសម្រស់ច្រើនជាងទៅលើការរៀនសូត្រ និងពង្រឹងសមត្ថភាពរបស់ខ្លួនទៅទៀត។ កញ្ញាបញ្ជាក់ថា៖ "កាលពីពេលកន្លងទៅ យើងបានរៀបចំនូវកម្មវិធីយុវជនឆ្នើម ប៉ុន្តែអ្នកចូលរួមមានត្រឹមតែ ៣០០នាក់ ទេតែ បើប្រៀបធៀបទៅនឹងការប្រឡងសម្រស់ ដូចជាប្រ៉េស្ស៊ីនោះ គឺមិនអាចប្រៀបធៀបបានទេ។ យុវជនគាំទ្រការប្រកួតសម្រស់ច្រើនមែនទែន"។ កញ្ញាបន្តទៀតថា បើយើងមិននិយាយអំពីអ្នកចូលរួមអ្នកទស្សនានិងអ្នកគាំទ្រ អ្នកដែលចូលរួមលើកទឹកចិត្តវិញនោះ ក៏ខុសគ្នាច្រើនផងដែរ។ ការចូលរួមគាំទ្រកម្មវិធីបែបប្រកួតសមត្ថភាព ហាក់ដូចជានៅតិចជាងកម្មវិធីប្រកួតប្រជែងបែបសម្រស់។

យុវនារីឈាន ដានី យុវនិស្សិតផ្នែកគណនេយ្យក៏ប្រាប់ឱ្យដឹងថា សម្រាប់នាង សម្រស់ និងសមត្ថភាពជារឿងពីរដែលដើរទន្ទឹមគ្នា។ រីឯសិល្បៈវប្បធម៌ជាតិ និងបរទេស ក៏ខ្ញុំចូលចិត្តទាំងពីរដែរ តាមកាលៈទេសៈជាក់ស្តែង។

អ្នកសម្របសម្រួលនៃក្រុមប្រឹក្សាយុវជនកម្ពុជាប្រាប់ឱ្យដឹងទៀតថា ការជំរុញកម្មវិធីបណ្តុះបណ្តាលផ្នែកសិល្បៈ និងវប្បធម៌ជាតិ ដូចជា របាំប្រពៃណី និងចម្រៀងបុរាណនៅតាមសាលារៀនជាដើមនោះ គឺជារឿងមួយ ដែលគួរតែពិចារណា។ កម្មវិធីទាំងនេះ ជាមធ្យោបាយមួយក្នុងការទប់ស្កាត់ភាពភ្លើតភ្លើន ដើម្បីកុំឱ្យយុវជន និងយុវនារី ទទួលតែវប្បធម៌បរទេសច្រើនពេក។

កញ្ញាម៉ៅ ពុទ្ធារត្ន័ ក៏បានបន្ថែមដែរថា កម្មវិធីបណ្តុះបណ្តាលនេះអាចនឹងផ្តល់ចំណេះដឹង និងឱ្យយុវជនដឹងខ្លះៗ អំពីសារៈសំខាន់នៃវប្បធម៌របស់ជាតិ។ កញ្ញាបញ្ជាក់ថា៖ "វប្បធម៌បរទេស គឺជាអ្វីដែលពួកគេកំពុងតែទទួលហើយ។ ប៉ុន្តែការបណ្តុះបណ្តាលខាងវិស័យសិល្បៈ និងវប្បធម៌ជាតិ ក៏អាចឱ្យពួកគេរក្សាបាននូវវប្បធម៌ជាតិរបស់ខ្លួននៅក្នុងខ្លួន ព្រមទាំង ចិត្តគំនិតរបស់ពួកគេផងដែរ"។

## កសិកម្ម

# វ៉ាក់សាំងគឺជាវិធានការការពារអុតក្តាមប្រសើរបំផុត

**ជាត សំភី**

លោកបណ្ឌិតមាឃ ប្រមូល អ្នកជំនាញកសិកម្ម នៃក្រុមហ៊ុនបាយអូមីន មានប្រសាសន៍ថាអុតក្តាម ជាជំងឺមួយ ដែលកើតនៅលើជើងសត្វពាហនៈ ដូច ជាគោ-ក្របី ។ ជំងឺនេះមានរោគសញ្ញាដំបៅក្រចក រលួយក្រចក និងធ្វើឱ្យសត្វ វាដើរលែងរួចតែម្តង ។ មិនត្រឹមតែប៉ុណ្ណោះ គេសង្កេតឃើញមានពង បែក លើមាត់ច្រមុះ និងសត្វហៀរទឹកមាត់ជាដើម ។

លោកបណ្ឌិតមាឃ ប្រមូល ប្រាប់ថា ជំងឺនេះ អុតក្តាមនេះច្រើនតែផ្ទុះឡើង នៅរដូវវស្សា ដែល បណ្តាលមកពីការចម្លងពីសត្វមួយទៅសត្វមួយ ។ លោករៀបរាប់ថា តាមទម្លាប់ ប្រជាកសិករតែង តែចិញ្ចឹមគោ-ក្របី ដោយព្រលែងពួកវា ឱ្យដើរស៊ី ស្មៅនៅពាសវាលពាសកាល ។ ដូច្នេះសត្វពាហណៈ ពួកគាត់ងាយនឹងឆ្លងជំងឺផ្សេងៗណាស់ជាពិសេស ឆ្លងពីសត្វដែលមានមេរោគតែមិនទាន់ចេញរោគ សញ្ញា ឱ្យឃើញនៅឡើយ ។

សម្រាប់ការកើតជំងឺអុតក្តាម ទោះបីជាវាមិន ធ្វើឱ្យគោក្របីងាប់ភ្លាមៗ ដូចជា ជំងឺសាទឹក ឬជំងឺ ប៉េស្ត ។ ប៉ុន្តែជំងឺនេះធ្វើឱ្យប៉ះពាល់ដល់សត្វចិញ្ចឹម ទាំងនោះ ពិសេសវាបង្អាក់ដល់ការលូតលាស់របស់ សត្វ ធ្វើឱ្យខ្វះខាតកម្លាំងអូសទាញ ឬកសិករត្រូវ ខាតពេលដើម្បីមើលថែសត្វគោ-ក្របីរបស់គាត់ ។

មិនត្រឹមតែប៉ុណ្ណោះក្នុងករណីធ្ងន់ធ្ងរ សត្វអាច



មិនគួរចិញ្ចឹមគោឱ្យដើរពាសវាលពាសកាល

Photo : P. Nith

ស្លាប់ដោយសារជំងឺអុតក្តាមដែរ ។ លោកបណ្ឌិត មាឃ ប្រមូល គូសបញ្ជាក់ថា: "ការចាក់វ៉ាក់សាំង ទៀងទាត់ គឺជាវិធានការការពារ យ៉ាងល្អប្រសើរ សម្រាប់ជំងឺអុតក្តាម" ។ លោកបណ្ឌិតបន្តថា វ៉ាក់-សាំងជំងឺអុតក្តាម មានលក់នៅលើទីផ្សារ ឬក៏តាម មន្ទីរកសិកម្មនៅក្នុងតំបន់មួយចំនួន ។ លោកបណ្ឌិត សង្កត់ធ្ងន់ថា ការចាក់វ៉ាក់សាំងការពារ គឺជាវិធាន ការមានប្រសិទ្ធភាពបំផុត ដើម្បីទប់ស្កាត់ជំងឺអុត-ក្តាម ។ ចំណែកការព្យាបាល គឺគ្រាន់តែបន្ទាប់បន្សំ ដើម្បីផ្សះដំបៅតែប៉ុណ្ណោះ ។ តាមទម្លាប់ពីមុនមក កសិករតែងយកដើមរមៀតមកស្ងោររំងាស់ក្នុងទឹក មួយលីត្រ ។ គាត់យកក្រណាត់មកជ្រលក់ទឹកហ្នឹង ហើយជុសនៅលើស្នាមដំបៅ ដែលសត្វកើត ។

លោកបណ្ឌិតបន្តទៀតថា កសិករគួរចិញ្ចឹមសត្វ ពាហនៈនៅទីធ្លាមួយ និងរៀបចំទ្រុងត្រឹមត្រូវ ។ កសិករមិនគួរព្រលែងសត្វដើរពាសវាលពាសកាល ទេ ដែលធ្វើឱ្យពួកវាងាយឆ្លងជំងឺមកពីសត្វផ្សេងៗ ជាពិសេសនៅមុនរដូវផ្ទុះជំងឺអុតក្តាមនេះ ។ ជាការ ល្អបំផុត កសិករអាចដាំស្មៅ ដើម្បីយកឱ្យគោក្របី គាត់ស៊ីតែម្តង ។ ការធ្វើដូច្នេះ វាអាចជំរុញការលូត លាស់របស់សត្វផង និងជាការការពារជំងឺផ្សេងៗកុំ ឱ្យកើតមានលើសត្វរបស់ពួកគាត់ផង ។

## បរិស្ថាន

# ដាំរុក្ខជាតិជុំវិញផ្ទះជាប្រយោជន៍ខ្លួនផ្ទាល់ និងបរិស្ថាន

លោកទេព ប៊ុននី នាយកប្រតិបត្តិនៅអង្គការ សង្គ្រោះសត្វព្រៃ មានប្រសាសន៍ថា: "ការដាំរុក្ខ-ជាតិនៅតាមគេហដ្ឋានមានប្រយោជន៍ណាស់" ។

លោកទេព ប៊ុននី បន្តថា រុក្ខជាតិគ្រប់ប្រភេទ បានផ្តល់ប្រយោជន៍ ពីរយ៉ាង គឺប្រយោជន៍ផ្ទាល់ និងមិនផ្ទាល់ ។ ប្រយោជន៍ផ្ទាល់ គឺប្រយោជន៍នៅ ចំពោះមុខ មានន័យថា ទីមួយ យើងដាំរុក្ខជាតិ ដើម្បីទ្រង់ទ្រង់ជីវិត ឬដើម្បីសោភ័ណភាព ដូចជា ដាំ ឈើហូបផ្លែ ឬដាំផ្កាជាដើម ។ ទីពីរប្រយោជន៍ ខាងការអប់រំ គឺយើងអាចប្រាប់កូនចៅ ឬបងប្អូន អំពីប្រភេទរុក្ខជាតិ ។ ប្រយោជន៍មិនផ្ទាល់ គឺគ្រប់ ប្រភេទរុក្ខជាតិទាំងអស់ សុទ្ធតែបានចូលរួមវិភាគ ទានទៅដល់ការទ្រទ្រង់លំនឹងបរិយាកាស ដែល ជាបរិស្ថានរស់នៅរបស់មនុស្ស ។

លោកទេព ប៊ុននី អះអាងថា សព្វថ្ងៃនេះពល-រដ្ឋខ្មែរសុទ្ធតែមានចំណាប់អារម្មណ៍ដាំរុក្ខជាតិ ។ ប៉ុន្តែជាទូទៅ គឺគាត់ទាញយកប្រយោជន៍ចំពោះ មុខ ។ តួយ៉ាងបើសិនគាត់ដាំផ្កាគឺដើម្បីតែការតែង លំអ ឬដាំឈើយកផ្លែហូប ។ ដូច្នេះយើងគួរ លើក ទឹកចិត្តគាត់ដាំឱ្យបានទូលំទូលាយ ។ យើងក៏អាច ពន្យល់គាត់ថាទោះជារុក្ខជាតិប្រភេទណាក៏ដោយ ប្រសិនបើគាត់ដាំ វាពុំមែនត្រឹមតែផ្តល់ប្រយោជន៍ ចំពោះមុខគាត់ប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏បានចូលរួម ចំណែកមួយទៀតក្នុងការគាំពារ ថែរក្សាបរិស្ថាន នៃភពផែនដីផងដែរ ។

**ជាត សំភី**



Photo : P. Samphy

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 7

## អង្គការ

# មណ្ឌលនិស្សិតផ្តល់ឱកាសយុវជនជនបទចូលរៀនឧត្តមសិក្សា

**ផាត សំភី**

យុវជន-នារី ៤៩នាក់ កំពុងស្នាក់នៅក្នុងមណ្ឌលនិស្សិតរបស់ព្រះសហគមន៍កាតូលិកនៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។ មណ្ឌលនេះជាទីជម្រក និងផ្តល់ឱកាសដល់យុវជននៅតាមព្រះសហគមន៍កាតូលិកនៅជនបទទូទាំងប្រទេសបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានានៅរាជធានីភ្នំពេញ។



Photos : P. Samphy

និស្សិតប្រើប្រាស់កុំព្យូទ័រដែលមានភ្ជាប់បណ្តាញអ៊ីនធឺណិតរួចជាស្រេចក្នុងការធ្វើស្វ័យសិក្សាដើម្បីបង្កើនចំណេះដឹងពួកគេ

មណ្ឌលនិស្សិតបានបង្កើតដំបូងនៅឆ្នាំ១៩៩៩ ដោយគំនិតផ្តួចផ្តើមរបស់លោកអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ លោកអេមីល ដេតម្ប។ ពេលនោះ មណ្ឌលនេះគ្រាន់តែជាអគារស្នាក់នៅក្នុងព្រះសហគមន៍កាតូលិកសន្តយ៉ូសែប នៅទីក្រុងភ្នំពេញ សម្រាប់និស្សិតស្នាក់នៅបន្តការសិក្សា នៅឧត្តមសិក្សា។ លុះដល់ឆ្នាំ២០០១ ទើបផ្លាស់ ប្តូរមកដល់ទីតាំង សព្វថ្ងៃ។

លោកបូជាចារ្យ យ៉ូហាន អេវ៉ាន់ អាស្លី ជាអ្នកសម្របសម្រួលមណ្ឌលនិស្សិតកម្ពុជា មានប្រសាសន៍ថា ការបង្កើតមណ្ឌលសម្រាប់និស្សិតនេះ មានគោលដៅ ទីមួយ គឺជួយនិស្សិតដែលមកពីគ្រួសារក្រីក្រឱ្យមានឱកាសបានរៀនសូត្រនៅមហាវិទ្យាល័យ។ ទីពីរ យើងចង់ជួយយុវជន ដែលមានជំនឿខាងគ្រីស្តសាសនាឱ្យអាចទទួលចំណេះដឹងខ្ពង់ខ្ពស់ក្រោយមកពួកគេ ក៏អាចអនុវត្តជំនឿរបស់គេក្នុងមុខរបរជាក់ស្តែង។ ទីបី យើងមានបំណងឱ្យយុវជនស្គាល់ពីការរស់នៅជាក្រុម គឺចេះស្រឡាញ់គ្នា និងអត់អោនឱ្យគ្នា។ ដូច្នេះពួកគេអាចរស់នៅក្នុងសង្គមគ្រួសាររបស់ពួកគេប្រកបដោយសុភមង្គលនៅថ្ងៃអនាគត។

ជារៀងរាល់ឆ្នាំ មណ្ឌលនិស្សិតធ្វើការជូនដំណឹងដល់ព្រះសហគមន៍កាតូលិកគ្រប់ខេត្ត-ក្រុង ដើម្បីដាក់ពាក្យប្រឡងអាហារូបករណ៍ចូលស្នាក់នៅ និងរៀនសូត្រ។ មុខវិជ្ជាដែលប្រឡង មានគណិតវិទ្យាវប្បធម៌ទូទៅ និងភាសាអង់គ្លេស ហើយបន្ទាប់មកមណ្ឌលនិស្សិតមានការធ្វើសម្ភាសន៍ ដើម្បីចង់ដឹងអំពីស្ថានភាពគ្រួសារ និងទឹកចិត្តប្តេជ្ញាខិតខំរៀនរបស់ពួកគេ។ ក្រោយពីទទួលបានអាហារូបករណ៍ និស្សិតៗទទួលបានការស្នាក់នៅ សម្ភារៈរៀនសូត្រ កុំព្យូទ័រ អ៊ីនធឺណិត ម្ហូបអាហារ និងការបង់ថ្លៃឱ្យសាលារយៈពេលបួនឆ្នាំតែម្តង។

កញ្ញាហ៊ុនសារ៉ែន អាយុ នាយិកាមណ្ឌលនិស្សិតកម្ពុជា និយាយថា : "គុណភាពគឺជាកត្តាចម្បង។ ដូច្នេះទើបយើងខិតខំគ្រប់គ្រងវិន័យឱ្យបានត្រឹមត្រូវ និងបង្កើតកម្មវិធីផ្សេងៗ ដើម្បីបង្កើនចំណេះដឹងទូទៅរបស់និស្សិត"។ កញ្ញាហ៊ុន សារ៉ែន បន្តថា យើងបង្កើតវគ្គសិក្ខាសាលាផ្សេងៗ ដូចជា វគ្គអប់រំសុខភាពផ្លូវចិត្ត វគ្គសិក្ខាភាសាអង់គ្លេស និងក្លឹបនយោបាយដែលនិស្សិតទាំងអស់ត្រូវធ្វើជជែកវែកញែកដេញដោលគ្នានៅលើប្រធានបទផ្សេងៗដែលទាក់ទឹងនយោបាយសង្គម និងសេដ្ឋកិច្ច។

លោកគីម យុនឡាង មានស្រុកកំណើតនៅភូមិចម្លាក់ ឃុំចក់ ស្រុកអូររាំងឪ ខេត្តកំពង់ចាម។ ក្នុងនាមជានិស្សិតរៀននៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោកនិយាយថា: "បើគ្មានមណ្ឌលនេះទេ ខ្ញុំប្រហែលជាគ្មានឱកាសមករៀននៅមហាវិទ្យាល័យ នៅទីក្រុងភ្នំពេញទេ ដោយសារគ្រួសាររបស់ខ្ញុំក្រីក្រ"។ លោកគីម យុនឡាងបន្តថា មណ្ឌលបានកែប្រែខ្ញុំពីការមើលឃើញអំពីតែខ្លួនឯងមកមើលឃើញអំពីសង្គមបានច្រើនជាងមុន។ លោកគីម យុនឡាង បន្ថែមថា ក្រៅពីផ្តល់មូលដ្ឋានសម្ភារៈ មណ្ឌលនិស្សិតបានផ្តល់ជំនួយផ្នែកស្មារតីដល់យើងផងដែរពោលគឺយើងអាចដកស្រង់បទពិសោធន៍អំពីការរស់នៅជាមួយមិត្តភក្តិ និងដឹងអំពីការរស់នៅជាជីវិតគ្រីស្តបរិស័ទ។



លោកញឹក ញឿន គឺជានិស្សិតផ្នែកទស្សនវិជ្ជានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោកមានដើមកំណើត នៅឯភូមិកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ លោកនិយាយថា មណ្ឌលនិស្សិតនេះបានផ្តល់ឱកាសឱ្យយុវជន ដែលមកពីបណ្តាខេត្ត។ មណ្ឌលបានកែប្រែយើងដែលជាយុវជនកសិករឱ្យអាចចាប់យកចំណេះដឹងខ្ពស់ៗ តាមសកលវិទ្យាល័យ។ មិនត្រឹមតែប៉ុណ្ណោះមណ្ឌលបានអប់រំ យើងនូវគុណធម៌តាមរយៈអប់រំឱ្យស្រឡាញ់រាប់អានគ្នាទៅវិញទៅមក និងការបើកចិត្តឱ្យទូលាយ ក្នុងការទទួលកំហុសគ្នា និងកែតម្រូវគ្នា។

កញ្ញា នីមផល្លី គឺជានិស្សិតជំនាញធនាគារ និងហិរញ្ញវត្ថុនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ កញ្ញាមានស្រុកកំណើតនៅភូមិចេក ឃុំជម្ពូវន្ត ស្រុកជុំគិរី ខេត្តកំពត។ កញ្ញានិយាយថា : "ប្រសិនបើគ្មានមណ្ឌលនេះខ្ញុំអាចនៅផ្ទះធ្វើតែស្រែ"។ កញ្ញាបន្តថា នៅទីនេះ យើងរៀនរស់នៅក្នុងវិន័យ និងច្បាប់ទម្លាប់ត្រឹមត្រូវដែរ។

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 8





Photo : S. Philong

## ខាន់ ភីរម្យ

### កម្ពុជាសម្ពោធផ្លូវដែក១១០គម

ផ្លូវដែកមួយកំណាត់ប្រវែង ១១០ គម ភ្ជាប់ពីភ្នំពេញទៅកាន់ទូកមាស ខេត្តកំពត បានត្រូវប្រកាសបើកឱ្យធ្វើចរាចរណ៍ ក្រោមល្បឿនកំណត់ត្រឹម ៥០គម ក្នុងមួយម៉ោង ក្រោយពេលជួសជុលរួចរាល់ហើយ ។

លោកតូច ចាន់កុសល រដ្ឋលេខាធិការក្រសួងសារធារណការ និងដឹកជញ្ជូន មានប្រសាសន៍ថា ក្នុងដំណាក់កាលដំបូង សេវាកម្មដឹកជញ្ជូន តាមផ្លូវដែកមួយកំណាត់នេះទទួលត្រឹមតែស៊ីម៉ង់ប៉ុណ្ណោះ ។

ផ្លូវដែកនៅកម្ពុជា មានប្រវែងសរុប ៦៥០គម ដោយភ្ជាប់ពីភ្នំពេញទៅកាន់ព្រំដែនថៃ និងពីភ្នំពេញទៅកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ ។

តាមគម្រោង កំណាត់ផ្លូវដែកពីទូកមាសទៅកាន់ខេត្តព្រះសីហនុនឹងដំណើរការនៅក្នុងឆ្នាំ២០១១ ហើយផ្លូវដែកទាំងអស់នឹងត្រូវដំណើរការទាំងស្រុងក្នុងឆ្នាំ២០១៣ ។

ការស្តារផ្លូវដែកទាំងអស់ នឹងត្រូវចំណាយ ថវិកាប្រមាណ ១៤១,៦ លានដុល្លារ ដោយថវិកានេះ បានមកពីជំនួយ ឥតសំណង ប្រាក់កម្ចី និង ថវិកាបដិភាគរបស់កម្ពុជា ។

### កម្ពុជារៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន

កាលពីថ្ងៃទី២៣ ខែតុលា មុននេះ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន លើកទី ៣២ ។ កិច្ចប្រជុំនេះធ្វើនៅវិមានរដ្ឋាភិបាលដែលទើបតែសម្ពោធថ្មីៗ នេះ នៅរាជធានីភ្នំពេញ ។

ឯកឧត្តមច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ មានប្រសាសន៍ថា កិច្ចប្រជុំនេះផ្តោតទៅលើបច្ចេកទេស និងនីតិវិធីរដ្ឋបាលពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ការផ្លាស់ប្តូរព័ត៌មាន និងការកែច្នៃផលិតកម្មកសិកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ។

ក្រៅពីកិច្ចប្រជុំនៃបណ្តារដ្ឋមន្ត្រីក្រសួងកសិកម្ម និងព្រៃឈើរបស់អាស៊ាន ទាំង១០ប្រទេស កម្ពុជាក៏មានរៀបចំនូវកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រសួងកសិកម្ម និងព្រៃឈើអាស៊ាន និងបូកបី គឺចិន ជប៉ុន និងកូរ៉េខាងត្បូង លើកទី ១០ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-ចិនលើកទី២ ផងដែរ ។

### ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់មូលនិធិដល់កម្ពុជា ១១៧លានដុល្លារ

ធនាគារអភិវឌ្ឍន៍អាស៊ី និងរាជរដ្ឋាភិបាល កម្ពុជា កាលពីថ្ងៃទី២២ ខែតុលា បានចុះកិច្ចព្រមព្រៀងលើជំនួយឥតសំណង និងប្រាក់កម្ចីសម្រាប់គម្រោង៤ ក្នុងទឹកប្រាក់សរុប ១១៧លានដុល្លារ ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងក្រោមអធិបតីភាពរបស់ឯកឧត្តមគាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនិងលោកគូនីអូ សឹងហ្គា អគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ីអាគ្នេយ៍នៃធនាគារអភិវឌ្ឍន៍អាស៊ី ។

គម្រោងដែលទទួលមូលនិធិទាំង៤នោះ រួមមាន គម្រោងកែលំអផ្លូវជនបទ កម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងធនធានទឹក កម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់អភិវឌ្ឍន៍ជនបទ និងកម្មវិធីលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច ។

## ផ្ទុះមហាកូដកម្មនៅប្រទេសបារាំងព្រោះរដ្ឋាភិបាលពន្យាអាយុចូលនិវត្តន៍




Photo : DR

មហាកូដកម្មជាច្រើន បានផ្ទុះឡើងនៅប្រទេសបារាំង ក្រោយពេលដែលលោកនីកូឡា ហ្សាកូហ្ស៊ី ជាប្រធានាធិបតីរបស់ប្រទេសនេះ បានសម្រេចពន្យាអាយុចូលនិវត្តន៍របស់បុគ្គលិកទទួលប្រាក់ខែ ។ មហាកូដកម្មនេះបានកើតមានឡើងកាលពីពាក់កណ្តាលខែតុលាមុននេះ ក្រោមការដឹកនាំដោយបណ្តាសហជីពនានានៅទូទាំងប្រទេសមួយនេះ ។

តាមទីភ្នាក់ងារព័ត៌មានស៊ីនហួរ បានឱ្យដឹងថា កូដកម្មនេះ មានអ្នកចូលរួមប្រមាណជាមួយលាននាក់ ។ អ្នកធ្វើការតវ៉ា ក៏បានដង្ហែក្បួននៅតាមដងផ្លូវនានា ក្រោយពេលដែលរដ្ឋបាលរបស់លោកប្រធានាធិបតីសាកូហ្ស៊ី បានសម្រេចពន្យាអាយុចូលនិវត្តន៍ពី៦០ឆ្នាំ ទៅ៦២ឆ្នាំ ។

លោកនីកូឡាសាកូហ្ស៊ី បានហៅកូដកម្មនេះថាជាសកម្មភាពបំផ្លាញសេដ្ឋកិច្ចរបស់ប្រទេសជាតិ ហើយថែមទាំងបានធ្វើឱ្យប៉ះពាល់ទៅដល់សន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងប្រទេស ។

## អាម៉េរិកប្រកាសផ្តល់ជំនួយ ២ពាន់លានដុល្លារទៅដល់ប្រទេសប៉ាគីស្ថាន

រដ្ឋាភិបាលអាម៉េរិកបានថ្លែងប្រកាសជាផ្លូវការថាខ្លួននឹងផ្តល់ជំនួយយោធា ដែលមានទឹកប្រាក់ចំនួន ២ពាន់លានដុល្លារទៅឱ្យប្រទេសប៉ាគីស្ថាន ដើម្បីឆ្លើយតបនឹងការបង្ក្រាបអំពើភេរវកម្ម និងការប្រយុទ្ធប្រឆាំងនឹងក្រុមនិយមជ្រុលក្នុងប្រទេសនេះ ។

លោកស្រីហ៊ីឡារី គ្លីនតុន រដ្ឋមន្ត្រីការបរទេសបានត្រូវគេដកស្រង់សំដីថា រដ្ឋាភិបាលរបស់លោកស្រីនឹងស្នើសុំទៅសភា ដើម្បីអនុម័តសម្រាប់ជួយដល់វិស័យយោធានៅក្នុងប្រទេសនេះពីឆ្នាំ ២០១២ ដល់ឆ្នាំ២០១៦ ។

ប្រភពព័ត៌មានបរទេស បានឱ្យដឹងថា នេះគឺជាកញ្ចប់ជំនួយថ្មីមួយ ដែលអាម៉េរិកសន្យាផ្តល់ឱ្យប្រទេសនេះ ក្រោយពេលដែលកម្មវិធីជំនួយមួយ ដែលមានទឹកប្រាក់រហូតទៅដល់ទៅ៧,៥ពាន់លានដុល្លារ ត្រូវបានរដ្ឋាភិបាលអាម៉េរិកធ្វើអនុម័តកាលពីខែមុនសម្រាប់ជួយដល់ផ្នែកស៊ីវិលដូចជា ការសាងសង់សាលារៀន និងហេដ្ឋារចនាសម្ព័ន្ធក្នុងរយៈ ពេល ៥ឆ្នាំ រួចហើយនោះ ។

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 9



# មុខវិជ្ជាវិទ្យាសាស្ត្រផ្តល់ការងាយស្រួលប្រឡងអាហារូបករណ៍

**ខាន់ ភីរម្យ**

*អាហារូបករណ៍បរទេស គឺជាក្តីស្រមៃរបស់និស្សិតជាច្រើនដើម្បីកសាងអនាគតមួយដ៏ល្អរបស់ពួកគេទៅថ្ងៃអនាគត។ ដូច្នេះនៅលេខនេះ អ្នកនាំសារ សូមណែនាំមិត្តអ្នកអានឱ្យជួបនឹង លោកហេង វុត្ថា ដែលជាអតីតនិស្សិតផ្នែកវិស្វករនៅជប៉ុនមួយរូប ដើម្បីឱ្យមិត្តអ្នកអានបានជ្រាបថា តើធ្វើយ៉ាងម៉េចដើម្បីអាចប្រឡងទទួលបានអាហារូបករណ៍ ?*

**អ្នកនាំសារ : តើលោកទទួលអាហារូបករណ៍សិក្សាលើមុខជំនាញអ្វីនៅក្នុងប្រទេសជប៉ុន ហើយលោកចេញទៅសិក្សាពីឆ្នាំណា ?**

**លោកហេង វុត្ថា** : ខ្ញុំទទួលបានអាហារូបករណ៍ទៅសិក្សាផ្នែកវិស្វករសំណង់ស៊ីវិលនៅប្រទេសជប៉ុន នៅក្នុងឆ្នាំ២០០១ ហើយបានបញ្ចប់ការសិក្សានៅក្នុងឆ្នាំ២០០៦ ។

**អ្នកនាំសារ : តើអាហារូបករណ៍នៅជប៉ុនគឺជាក្តីស្រមៃរបស់លោកឬ ? ហើយតើធ្វើយ៉ាងម៉េចទើបបានលោកអាចជាប់អាហារូបករណ៍នេះបាន ?**

**លោកហេង វុត្ថា** : ក្នុងនាមជាសិស្សម្នាក់ដែលសិក្សានៅតំបន់ជនបទមួយនៅកម្ពុជា អាហារូបករណ៍សិក្សានៅបរទេស មិនមែនជាក្តីស្រមៃរបស់ខ្ញុំទេ ដោយសារយើងខ្វះព័ត៌មានទាក់ទងនឹងបញ្ហានេះ និងយើងអត់សូវចេះភាសាបរទេសជាដើម ។ នៅពេលខ្ញុំបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យនៅពាមរណ៏ ខេត្តព្រៃវែង ខ្ញុំបានបន្តការសិក្សាផ្នែកខាងសំណង់ស៊ីវិលនៅឯវិទ្យាស្ថានបច្ចេកទេសកម្ពុជា ។ នៅពេលសិក្សានៅទីនោះបានដល់ឆ្នាំទីបី ខ្ញុំទទួលព័ត៌មានពីក្រសួងអប់រំអំពីកម្មវិធីអាហារូបករណ៍សិក្សានៅជប៉ុននោះ ខ្ញុំក៏ដាក់ប្រឡងដោយមិនគិតថាជាប់ទេដោយសារខ្ញុំមានបញ្ហាភាសា ។ ប៉ុន្តែដល់ពេលប្រឡង គេពុំផ្តោតទៅលើភាសាទេ គេផ្តោតជាសំខាន់ទៅលើជំនាញបច្ចេកទេស ខ្ញុំក៏ជាប់ទៅ ។



លោកហេង វុត្ថា ថតរូបអនុស្សាវរីយ៍នៅសកលវិទ្យាល័យបច្ចេកវិទ្យាណាហ្គាអូកៈ ជប៉ុន

**អ្នកនាំសារ : តើកត្តាអ្វីដែលធ្វើឱ្យលោកអាចទទួលអាហារូបករណ៍នេះបាន ?**

**លោកហេង វុត្ថា** : អាហារូបករណ៏ វាមានច្រើនប្រភេទតាមប្រទេសដែលភាគច្រើន គេទាមទារឱ្យមានចំណេះដឹងផ្នែកភាសារអង់គ្លេស ។ តែសម្រាប់អាហារូបករណ៏ដែលខ្ញុំទទួលបាននេះ គឺគេអត់សូវផ្តោតទៅលើភាសានោះទេ គេផ្តោតតែនៅលើមុខវិជ្ជាវិទ្យាសាស្ត្រតែប៉ុណ្ណោះ ។ ដូច្នេះហើយទើបនេះគឺជាឱកាសមួយដែលខ្ញុំបានទទួល ។

**អ្នកនាំសារ : តើលោកមានអ្វីផ្តាំផ្ញើទៅសិស្សនៅតំបន់ជនបទទាក់ទងនឹងការរកអាហារូបករណ៏ ?**

**លោកហេង វុត្ថា** : អាហារូបករណ៏បរទេស គឺគេផ្តល់ឱកាសស្មើៗគ្នាដល់និស្សិតទាំងអស់ ។ ប៉ុន្តែអ្វីដែលខុសគ្នានោះ គឺសិស្សនៅជនបទតែងជួបប្រទះនូវឧបសគ្គនោះ ដូចជាកង្វះខាតនូវព័ត៌មានផ្សេងៗ និងបញ្ហាភាសា ។ ប៉ុន្តែបើតាមបទពិសោធន៍របស់ខ្ញុំ ចំណុចខ្វះខាតទាំងនោះ វាក៏មិនមែនជារនាំងទាំងអស់នោះទេចំពោះសិស្សនៅតំបន់ជនបទ ។ ភាសាជាពិសេស គឺអង់គ្លេសនោះ គឺគេតម្រូវតែទៅលើមុខវិជ្ជាផ្នែកសង្គមទេ ។ ប៉ុន្តែសម្រាប់ផ្នែកបច្ចេកទេសវិញ មិនសូវទេសំខាន់ដាច់ខាតនោះទេ ។ ទោះបីជាយ៉ាងណា យើងក៏ត្រូវពូកែមុខវិជ្ជាវិទ្យាសាស្ត្រមួយចំនួនផងដែរដូចជា រូបវិទ្យា គីមីវិទ្យា គណិតវិទ្យា ។ មុខវិជ្ជាទាំងនេះ គឺជាមូលដ្ឋានដែលវាធ្វើឱ្យយើងអាចនឹងប្រឡងអាហារូបករណ៏បានទេ ។



Photo : DR

ក្រុមនិស្សិតខ្មែរទៅសិក្សានៅប្រទេសជប៉ុន។ ការបញ្ជូននិស្សិតទៅសិក្សានៅបរទេស ឬប្រទេសអភិវឌ្ឍន៏ គឺជាមធ្យោបាយអភិវឌ្ឍធនធានមនុស្សដ៏ប្រសើរ ដើម្បីបម្រើឱ្យការកសាងប្រទេសជាតិទៅថ្ងៃអនាគត។

## ប្រវត្តិលោកហេង វុត្ថា

លោកហេង វុត្ថា គឺជាវិស្វករជំនាញក្នុងការដ្ឋានមួយនៅកំពង់ផែអន្តរជាតិ ខេត្តព្រះសីហនុ។ លោកក៏ជាបុគ្គលិកក្នុងក្រុមហ៊ុនសំណង់ឯកជនមួយ ក្រោយពេលដែលលោកបានបញ្ចប់ការសិក្សានៅប្រទេសជប៉ុន។

លោកហេង វុត្ថា កើតនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៨១។

ក្រោយពីបានបញ្ចប់ការសិក្សានៅវិទ្យាល័យពាមរណ៏ ខេត្តព្រៃវែង ក្នុងឆ្នាំ១៩៩៨ លោកបានបន្តការសិក្សានៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជារហូតដល់ឆ្នាំទី៣ លោកបានដាក់ពាក្យប្រឡង ហើយក៏បានទទួលអាហារូបករណ៏ទៅសិក្សាលើមុខជំនាញវិស្វករសំណង់ស៊ីវិលនៅប្រទេសជប៉ុនតាំងពីឆ្នាំ២០០១ ហើយលោកបានត្រឡប់មកវិញកាលពីដើមឆ្នាំ២០០៩។

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 10



# សង្គមស៊ីវិល : ភាពក្រីក្រនៅតែជាឧបសគ្គក្នុងការជំរុញ

**ខាន់ ភីរម្យ**



បណ្ដាសង្គមស៊ីវិលដែលកំពុងធ្វើការជាមួយនិងកុមារងាយរងគ្រោះមួយចំនួន នៅកម្ពុជា អះអាងថា ផែនការអប់រំដើម្បីទាំងអស់គ្នា គឺអាចសម្រេចទៅបាន ។ ប៉ុន្ដែភាពក្រីក្រ និងបញ្ហាខ្លះទៀតនៅតែជារនាំងចំពោះផែនការនេះ ។

លោក កេតុ ច័ន្ទតូ ទីប្រឹក្សាអប់រំរបស់អង្គការផ្លែន(Plan) មានប្រសាសន៍ថា ផ្អែកលើស្ថិតិ យើងសង្ឃឹមថា ផែនការអប់រំដើម្បីទាំងអស់គ្នា ក្នុងឆ្នាំ២០១៥ខាងមុខ អាចនឹងសម្រេចបាន យ៉ាងហោចណាស់ ក៏៩០%ដែរ ។ លោកប្រាប់ឱ្យដឹងថា ក្នុងឆ្នាំ២០១០នេះ ស្ថិតិបង្ហាញថា ក្នុងចំណោមកុមារគ្រប់ចូលរៀន ដែលមាននៅក្នុងប្រទេស ប្រមាណជាង ២លាននាក់ អត្រាដែលបានចុះឈ្មោះចូលរៀនមានប្រមាណជាពី ៩៥% ទៅ៩៦% ។

បើទោះបីជាលោក ច័ន្ទតូ មានសុទិដ្ឋិនិយមនឹងផែនការអប់រំទាំងអស់គ្នា អាចនឹងសម្រេចទៅបានតាមផែនការ ដែលបានកំណត់យកឆ្នាំ២០១៥ គឺជាគោលក៏ដោយ ប៉ុន្ដែលោកបានបញ្ជាក់ថា ក្ដីកង្វល់និងការព្រួយបារម្ភនៅតែកើតមាន ។ លោកក៏បានគូសបញ្ជាក់ថា : "អ្វីដែលយើងព្រួយបារម្ភ គឺបញ្ហាគុណភាព ។ ថ្វីបើយើងមើលឃើញថាការចុះឈ្មោះរបស់កុមារបានសឹងតែទាំងអស់គ្នាមែន ។ តែយើងនៅតែឃើញថាមានការបោះបង់ការសិក្សា ។ ម្យ៉ាងទៀត សាលាមួយចំនួននៅខ្វះខាតគ្រូ ។ ចំណែកឯសាលាមួយចំនួនទៀត សមត្ថភាពរបស់គ្រូនៅមានកម្រិតជាដើម" ។ លោកបន្ដទៀតថា ការចុះឈ្មោះចូលរៀន គឺបានទាំងអស់គ្នាហើយ ។ តែអត្រាបោះបង់ការសិក្សាវិញ គឺនៅតែមាន ។ ជាក់ស្ដែងក្នុងឆ្នាំ២០១០នេះ អត្រាបោះបង់ការសិក្សាមានប្រមាណជា៨,៥% ។ ចំណែកបញ្ហាគុណភាពសិក្សានៅតែជាបញ្ហាចោទ ។ លោកក៏បន្ថែមថា សាលាមួយចំនួនមានសិស្ស តែអត់មានគ្រូ ហើយសាលាមួយចំនួនគ្រូដែលបម្រើការ ភាគច្រើន គឺជាគ្រូកិច្ចសន្យា ។

ជុំវិញបញ្ហាគុណភាព អត្រាបោះបង់ការសិក្សា និងកង្វះខាតគ្រូបង្រៀន លោកជា ពីដែន នាយកប្រតិបត្តិនៃអង្គការគាំពារកុមារ ដែលងាយទទួលរងគ្រោះមានប្រសាសន៍ថា គុណភាពជាបញ្ហាចោទមួយដែរ ។ លោកបញ្ជាក់ថា : "សិស្សជាច្រើនឡើងតែថ្នាក់ទេ ។ កុមារខ្លះបានរៀនដល់ថ្នាក់ទី៤ ថ្នាក់ទី៥ហើយ ពួកគាត់ក៏អត់ទាន់អាចអានអក្សរត្រង់ជួរនៅឡើយទេ" ។ លោកក៏បញ្ជាក់ថា ផែនការអប់រំទាំងអស់គ្នានេះ អាចសម្រេចទៅបានតាមផែនការកំណត់ក្នុងឆ្នាំ២០១៥ លុះត្រាតែគេអាចលុបបំបាត់ភាពក្រីក្រ និងបញ្ហាអសកម្មមួយចំនួនដូចជា អំពើហិង្សាក្នុងគ្រួសារជាដើម ។

លោកលើកឧទាហរណ៍ថា : "បើកំពុងតែរៀនៗឪពុកម្ដាយវាយគ្នា ឬរៀន គ្មានមានបាយបរិភោគតើឱ្យគេរៀន ដូចម្ដេចនឹងកើត?" ។

លោកពី ដែន មិនមានតួលេខបញ្ជាក់ទេ ។ ប៉ុន្ដែលោកមានប្រសាសន៍ថា សម្រាប់ខេត្ត-ក្រុងចំនួន៥ ដែលស្ថិតក្នុងគម្រោងការងាររបស់អង្គការលោក គឺក្រុងភ្នំពេញ តាកែវ កំពង់ឆ្នាំង សៀមរាប និងកំពង់ចាម ក្រុមការងារតាមបណ្ដាញភូមិសុវត្ថិភាពរបស់អង្គការរបស់លោក ក៏ពិនិត្យឃើញថា អត្រា

## ផែនការអប់រំដើម្បីទាំងអស់គ្នាចាយលុយ ៨៥៥ពាន់លានរៀល

ក្រសួងអប់រំ បានឱ្យដឹងថា ដើម្បីជំរុញផែនការនេះឱ្យសម្រេចបានក្នុងឆ្នាំ២០១៥ រដ្ឋាភិបាលបានគ្រោងនឹងចំណាយ ថវិកាប្រមាណជា៨៥៥ពាន់លានរៀល។

ប្រភពដដែលនោះបានឱ្យដឹងថា ការចំណាយទាំងនេះផ្ដោតទៅលើវិស័យរដ្ឋបាល កម្មវិធីអប់រំថ្នាក់មត្តេយ្យ ការអប់រំថ្នាក់មូលដ្ឋាន ការអប់រំក្រៅប្រព័ន្ធ កម្មវិធីអប់រំខាងអក្ខរកម្ម និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាដើម។ ចំណែកថវិកាទាំងអស់នេះទទួលបានពីថវិកាជាតិ និងថវិកាដែលបានមកពីប្រភពជំនួយរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល-ល-។

ការអប់រំដើម្បីទាំងអស់គ្នា គឺជាផែនការមួយដែលបង្កើតឡើងក្រោមគំនិតផ្ដួចផ្ដើមរបស់រដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០០២ ដើម្បីជំរុញលុបបំបាត់អនក្ខរកម្មក្នុងប្រទេស និងជំរុញឱ្យកុមារអាចទទួលបានការអប់រំយ៉ាងហោចណាស់ ក៏ឱ្យបានត្រឹមថ្នាក់ទី៩ ដែរ។

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 11

# ការជំរុញផែនការអប់រំដើម្បីទាំងអស់គ្នា



Photo : S. Philong

បោះបង់ការសិក្សារបស់សិស្ស អាចមានច្រើនជាងតួលេខ ខាងលើទៀតផង ជាពិសេស គឺកុមារី ។

លោកពីដែនប្រាប់ឱ្យដឹងថា សព្វថ្ងៃនេះអង្គការគាំពារកុមារ ដែលងាយទទួលរងគ្រោះកំពុងសិក្សាលើរបាយការណ៍មួយផ្សេងទៀតដើម្បីរកឱ្យឃើញនូវភាពងាយរងគ្រោះរបស់កុមារ នៅកម្រិតថ្នាក់ជាតិ នៅក្នុងខេត្តចំនួន៨ គឺស្វាយរៀង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ កោះកុង ក្រុងព្រះសីហនុ កំពង់ធំ និងខេត្តសៀមរាប ។

ការអប់រំដើម្បីទាំងអស់គ្នា គឺជាផែនការដើម្បីជំរុញឱ្យពលរដ្ឋក្នុងប្រទេសកម្ពុជាទាំងអស់ ទទួលបានការអប់រំ និងលុបបំបាត់ចោលនូវគ្រោះមិនចេះអក្សរ ។ ប៉ុន្តែទោះបីជាយ៉ាងណានៅតាមដងផ្លូវនៃដងមហាវិថីធំៗ នៅក្នុងរាជធានីភ្នំពេញ គេសង្កេតឃើញថា កុមារា-កុមារី ជាច្រើននាក់ កំពុងប្រកបរបរលក់ផ្កា ដើរសុំទាន ខាត់ស្បែកជើង និងរើសសំរាម ។ ចំណែកកុមារមួយចំនួនដោយសារតែជីវភាពក្រីក្រ ពួកគេមិនដែលនឹកពីការចូលរៀនដែរ ។

ជា ម៉ាប់ អាយុ ១៣ឆ្នាំ ជាកុមារដើរខាត់ស្បែកជើងតាមហាងកាហ្វេនៅភ្នំពេញ និយាយថា តាំងពីតូចមក រូបគេមិនដែលចូលសាលារៀនទេ ហើយក៏មិនចង់ចូលសាលារៀននោះដែរ ។

សព្វថ្ងៃនេះ ម៉ាប់រស់នៅជាមួយម្តាយដែលមានជំងឺប្រចាំកាយមួយរូប ។ ម៉ាប់មានបងប្អូនទាំងអស់ចំនួន ៣នាក់ រូបគេ ជាកូនទី២ ហើយក៏គ្មានបងប្អូនរបស់ម៉ាប់ណាម្នាក់បានចូលសាលារៀនទេ ។

ម៉ាប់បញ្ជាក់ថា: "ខ្ញុំចង់ទៅរៀនដែរ តែបើរៀនខ្ញុំបានអ្វីហូបនោះ" ។

លី ម៉ៅ អាយុ ១៥ឆ្នាំ ជាកុមារដើររើសសំរាមតាមចិញ្ចើមផ្លូវមួយរូប ប្រាប់ឱ្យដឹងថា រូបគេធ្លាប់ចូលរៀន តែស្អប់ឪពុកចុងគេពេក ក៏បានចាកចេញពីផ្ទះ ហើយមករស់នៅតាមចិញ្ចើមផ្លូវ ជាយូរមកហើយ ។ ម៉ៅ បញ្ជាក់ថា : "ឪចុងរបស់ខ្ញុំ វាយខ្ញុំ ។ ខ្ញុំខឹង ។ ខ្ញុំរត់ចេញមក ហើយរស់នៅជាមួយនិងមិត្តភក្តិ និងរើសអេតចាយដូចគ្នា នៅគ្រប់តែផ្លូវ" ។

កុមារម្នាក់ទៀតឈ្មោះសំណព្វ អាយុ ១២ឆ្នាំ ហាក់ដូចជាមានសំណាងជាងកុមារទាំងពីរខាងលើនេះបន្តិច ។ សព្វថ្ងៃនេះ គេដើរសុំទានផង និងបានរៀនផងដែរ ដោយមានការឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាលមួយ ។

សំណព្វ គឺជាក្មេងកំព្រារស់នៅជាមួយនិងម្តាយមីង ប៉ុន្តែត្រូវម្តាយមីងបង្ខំឱ្យរកប្រាក់ យ៉ាងហោចណាស់ក៏ឱ្យបាន ៤០០០រៀលដែរនៅក្នុងមួយថ្ងៃ ។ សំណព្វបញ្ជាក់ : "បើថ្ងៃណា ដែលខ្ញុំសុំគេអត់បាន ៤០០០រៀលទេ ។ ខ្ញុំច្បាស់ជាត្រូវរំពាត់ ហើយខ្ញុំក៏មិនអាចទៅរៀនបានដែរ" ។ សំណព្វនិយាយថា រូបគេតែងគេចពីផ្ទះបាត់ៗ ដោយចេញពីព្រលឹម និងចូលផ្ទះនាពេលអាធ្រាត ។ នៅពេលថ្ងៃសំណប់គេចទៅរៀន ហើយដើរសុំទាននៅពេលទំនេរ ។

ពាក់ព័ន្ធនឹងស្ថានភាពរបស់កុមារទាំងបីរូបខាងលើនេះលោកច័ន្ទតូប្រាប់ថា នេះគឺជាការពិត ។ នៅពេលបច្ចុប្បន្ននេះ យើងនៅតែឃើញមានកុមារ សុំទាននៅតាមដងផ្លូវនានា ។ ប៉ុន្តែទោះបីជាយ៉ាងណាក្នុងកិច្ចប្រឹងប្រែងជំរុញផែន ការអប់រំទាំងអស់គ្នាឱ្យទៅដល់គោលដៅនោះ អង្គការមួយចំនួនកំពុងធ្វើដំណើរការងាររបស់ពួកគេនៅលើបញ្ហានេះ ។

លោកប៉ែន សុជាតិ ទីប្រឹក្សាប្រធានផ្នែកសង្គមនៃអង្គការដើម្បីស្នាមញញឹមកុមារ មានប្រសាសន៍ថា ផែនការអប់រំទាំងអស់គ្នានេះអាចនឹង សម្រេចបាន ប្រសិនបើរដ្ឋាភិបាលសង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ចូលរួមជាមួយគ្នា ។ លោកក៏បញ្ជាក់ថា: "បើសិនយើងទាំងអស់គ្នាប្តេជ្ញាចិត្តនិងជួយតាមសមត្ថភាព ខ្ញុំគិតថា វាគ្មានឧបសគ្គទេ ។ ផែនការនេះ មិនមែនជាកាតព្វកិច្ចតែរដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាលទេ តែជាផែនការទាំងអស់គ្នា" ។ លោកបានបន្តថា អង្គការដើម្បីស្នាមញញឹមកុមារមកដល់ពេលនេះ បានជួយអតីតកុមារ ងាយរងគ្រោះ ប្រមាណជា២០០០នាក់ ឱ្យទទួលបាននូវការងារធ្វើតាមរយៈគម្រោងជាច្រើន គឺមានដូចជាគម្រោងអប់រំបណ្តុះបណ្តាលជំនាញអប់រំ ក្រៅផ្លូវការជាដើម ។ ឥឡូវអ្នកខ្លះអាចទទួលបានបៀវត្សរ៍រហូតដល់ទៅ ២០០០ដុល្លារ ក្នុងមួយខែក៏មាន ។ ក្រៅពីនោះ ក្នុងពេលបច្ចុប្បន្ន អង្គការកំពុងតែជួយដល់កុមារក្នុងកម្មវិធីប្រមាណជា៦០០០នាក់ ។ ពួកគេគឺជាកុមារមកពីគ្រួសារអ្នករើសអេតចាយ ក្មេងកំព្រា និងកុមារក្នុងគ្រួសារទីទាល់ក្រ-ល- ។

## បញ្ហាប្រឈមរបស់ផែនការអប់រំដើម្បីទាំងអស់គ្នា

លោកអ៊ុន សិរិទ្ធី នាយកប្រតិបត្តិនៃអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល មានប្រសាសន៍ថា បញ្ហាប្រឈមដែលអាចនឹងជះឥទ្ធិពលទៅលើផែនការអប់រំដើម្បីទាំងអស់គ្នា គឺមានបួនសំខាន់ៗ។

លោកប្រាប់ថា ភាពក្រីក្រគឺជារនាំងដ៏ធំ ដែលអាចនឹងរារាំងកុមារមួយចំនួន មិនឱ្យចូលសាលារៀន។ ហេដ្ឋារចនាសម្ព័ន្ធរបស់សាលាក៏ជាបញ្ហាដែរ។ ក្រៅពីនោះ ការចំណាយទៅលើការបង់ថ្លៃសិក្សាក្រៅផ្លូវការ ហើយនឹងអារម្មណ៍ និងសមត្ថភាពរបស់គ្រូ ក៏ជាចំណុចដែលគួរតែយកចិត្តទុកដាក់ និងជាបញ្ហាប្រឈមដែលអាចនឹងជះឥទ្ធពលទៅលើផែនការនេះផងដែរ។

លោកបន្តថា ក្រៅពីចំណុចទាំងអស់ខាងលើបញ្ហាគុណភាពក៏ជាបញ្ហាមួយ ដែលគេមិនគួរព្រងើយកន្តើយបានដែរ។ លោកបន្ថែមថា បើទោះបីជាអត្រាចុះឈ្មោះចូលរួមមានចំនួនជាង ៩០% តែផែនការអប់រំក៏មិនអាចសម្រេចទៅបានដែរ បើគេមិនគិតអំពីគុណភាពនោះ។

# ព័ត៌មានព្រះសហគមន៍កាតូលិក

## កិច្ចសំណេះសំណាលលើកដំបូងនៃអភិបាលភូមិភាគភ្នំពេញ

**អ៊ឹម សុខន**

លោកអភិបាលសុខកុមារ អូលីវីយេ ផ្មិតអ៊ីស្លែរ មានមតិសំណេះសំណាលទៅកាន់អស់លោកបូជា- ចារ្យ និងនិស្សិតទេវវិទ្យាល័យក្នុងពិធីអភិបូជាបិទ អង្គប្រជុំបូជាចារ្យភូមិភាគភ្នំពេញ កាលពីថ្ងៃទី១៩ ខែតុលា នៅព្រះសហគមន៍ផ្សារតូច ក្រុងភ្នំពេញ។

លោកអភិបាលបានមានប្រសាសន៍ថា: "មិនថា យើងជាអភិបាល បូជាចារ្យ ឬមានងារអ្វីនោះទេ គឺ យើងមាននាមតែមួយ គឺគ្រិស្តបរិស័ទ និងតួនាទីតែ មួយ គឺជាអ្នកបម្រើរបស់បម្រើ។ យើងត្រូវតែទុក ចង្កៀងអ្នកឱ្យភ្លឺ ដើម្បីដកសេចក្តីអាក្រក់ និងអំពើ បាបចេញពីខ្លួន ដោយរស់នៅ ជាមួយព្រះជាម្ចាស់ គ្រប់នាទី តាមរយៈគោលដៅរបស់ព្រះ សហគមន៍ គឺចូលរួមរស់នៅក្នុងក្រុមគ្រួសារដ៏បរិសុទ្ធ។"

នេះគឺជាការជួបជុំជាលើកដំបូងរវាងអស់លោក អភិបាលថ្មី និងអស់លោកបូជាចារ្យនៅក្នុងបំណង សំណេះសំណាលស្វែងយល់អំពីការងាររបស់លោក បូជាចារ្យ ដែលមានទទួលខុសត្រូវព្រះសហគមន៍ នីមួយៗ ក្នុងភូមិភាគនេះ។

ក្នុងមុខងារជាអភិបាលថ្មី លោកសុខកុមារ អូលី វីយេ ផ្មិតអ៊ីស្លែរ បានដាក់នូវទស្សនវិស័យ សេចក្តី ស្រឡាញ់ ការតស៊ូ ការបង្កើត គំនិតច្នៃប្រឌិត និង ការសហការគ្នា។ ដើម្បីសម្រេចឱ្យបានទស្សនៈនេះ លោកកំណត់កិច្ចប្រជុំរៀងរាល់២ខែម្តងជាមួយនិង ប ជាចារ្យបម្រើការតាមព្រះសហគមន៍នីមួយៗ។

ក្នុងកិច្ចសំណេះណែលនេះដែរ អស់លោកបាន រិះគិតលើលិខិតរបស់សម្តេចប៉ាប បេណេឌិក ទី១៦ សម្រាប់ថ្ងៃអាទិត្យទិវាបេសកកម្មពិលោក។លោក អភិបាលបានសំណូមពរប្រមូលយកប្រាក់ដង្វាយ នៅថ្ងៃនោះ ដើម្បីចូលរួមចំណែកជួយដល់ព្រះស- ហគមន៍ក្រីក្រជាសកល ដែលជាសញ្ញាសម្គាល់ថា ព្រះសហគមន៍នៅកម្ពុជាចូលរួមសកម្មភាពជាមួយ និងព្រះសហគមន៍សកលផងដែរ។


Photo : Kimsean

លោកអភិបាលសុខកុមារ អូលីវីយេ ផ្មិតអ៊ីស្លែរ បានទទួលអគ្គសញ្ញា តែងតាំងជាអភិបាល កាលពី ថ្ងៃទី ២០ មីនា ២០១០កន្លង ជាអភិបាលឧបត្ថម្ភក នៃអភិបាលព្រះសហគមន៍កាតូលិកភូមិភាគ។ នៅ ថ្ងៃទី១ ខែតុលា មុននេះ សម្តេចប៉ាបបេណេឌិក ទី ១៦ បានប្រគល់នូវមុខងារឱ្យលោកធ្វើជាអភិបាល នៃភូមិភាគភ្នំពេញពេញសិទ្ធិ ជំនួសលោកអភិបាល អេមីល ដេតម្ប ដែលត្រូវចូលនិវត្តន៍។

ពិធីផ្ទេរតំណែងជាផ្លូវការ ប្រព្រឹត្តទៅ នៅថ្ងៃទី ១៣ ខែវិច្ឆិកា នៅព្រះសហគមន៍ផ្សារតូច។

## សន្និបាតលោកអភិបាលថ្មី សម្រេចដោយជោគជ័យ

សមណៈក្រសួងប្រកាសដំណឹងល្អ ទៅកាន់ប្រ- ជាជននៃបុរីរ៉ូមបានរៀបចំនូវសន្និសីទមួយសម្រាប់ លោកអភិបាលថ្មីៗ ដែលទទួលការតែងតាំងបាន២ ឆ្នាំកន្លងមក នៅវិទ្យាល័យសន្តប៉ូល នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលីពីថ្ងៃទី៥-១៨ កញ្ញា ឆ្នាំ២០១០។

លោកអភិបាលចូលរួម មាន១០១រូប ដែលមក ពី៤០ប្រទេសជុំវិញពិភពលោក។ នៅទ្វីបអាហ្វ្រិក លោកអភិបាល មាន ៥៦រូប។ នៅទ្វីបអាស៊ី លោក អភិបាលមាន ៣៩រូប។ នៅទ្វីបអាម៉េរិកខាងត្បូង លោកអភិបាល មាន ៤រូប និងនៅទ្វីបអូសេអានី លោកអភិបាល មាន ២រូប ដែរ។

នៅទ្វីបអាស៊ី មានលោកអភិបាល ចូលរួមច្រើន ជាងគេ។ លោកអភិបាលមកពីប្រទេសឥណ្ឌា មាន ១០រូប។ វៀតណាម មាន ៩រូប។ ឥណ្ឌូណេស៊ីមាន ៦រូប។ ថៃមាន ៤រូប។ ចំណែកលោកអភិបាលមក ពីប្រទេសកម្ពុជា មានតែលោកអភិបាលសុខកុមារ អូលីវីយេ ផ្មិតអ៊ីស្លែរ ម្នាក់គត់។

នៅក្នុងអង្គសន្និបាតនេះ មានអ្នកឯកទេសមក និយាយអប់រំលោកអភិបាលថ្មីទាំងនោះ។

បាឋកថានីមួយៗមានរយៈពេល៤៥នាទី ហើយ មានសំនួរ-ចម្លើយ ៤៥នាទី ក្នុង ៤ភាសា គឺភាសា អ៊ីតាលី អង់គ្លេស បារាំង និងអេស្ប៉ាញ។ នៅរាល់ ពេលរសៀល មានចែកតាមក្រុមតាមភាសាទាំង៤ ហើយមកធ្វើរបាយការណ៍នៅអង្គប្រជុំធំ។

ក្រោយធ្វើសន្និសីទបាន ៩ថ្ងៃ លោកអភិបាលថ្មី មានឱកាសចូលគាល់សម្តេចប៉ាបបេណេឌិកទី១៦។ សម្តេចប៉ាបមានព្រះបន្ទូលទៅកាន់លោកអភិបាល ថ្មីថា: "មុខងារលោកអភិបាលគឺជាការផ្តល់សេចក្តី សង្ឃឹមឱ្យគ្រិស្តបរិស័ទ។ លោកត្រូវតែចែកអំណរ សប្បាយ និងរួមទុក្ខព្រួយជាមួយបងប្អូន និងមាន សេចក្តីមេត្តាករុណាដូចព្រះយេស៊ូ"។នាក្រោយមក ព្រះអង្គជួបលោកអភិបាលម្នាក់ៗ ទោះបីជាពេលខ្លី ប៉ុន្តែលោកអភិបាលទាំងអស់មានអំណរណាស់។

អង្គសន្និបាតបានបិទដោយលោកអភិបាល ទាំង អស់រួមគ្នាថ្វាយអភិបូជានៅឯមហាវិសាលវិហារ ក្រោមអធិបតីភាពលោកកាឌីណាល់អ៊ីវ៉ានឌីយេស នៅថ្ងៃសៅរ៍ ទី១៨ ខែកញ្ញា ឆ្នាំ២០១០។

លោកអភិបាលសុខកុមារ អូលីវីយេ ផ្មិតអ៊ីស្លែរ ចាត់ជាលោកអភិបាលដែលមានវ័យក្មេងជាងគេ ក្នុងចំណោមលោកអភិបាលទាំងអស់ដែលចូលរួម ហើយលោកទទួលការគាំទ្រ និងការលើកទឹកចិត្ត សម្រាប់មុខងារធ្វើជាអភិបាលរបស់លោកនៅព្រះ សហគមន៍កាតូលិកកម្ពុជា។

**របាយការណ៍ដោយលោកប៉ូល រឿងឆត្រជ័យ**

### លោកអភិបាលសួរសុខទុក្ខ សហគមន៍និយាយអង់គ្លេស

លោកអភិបាលសុខកុមារ អូលីវីយេ ផ្មិតអ៊ីស្លែរ បានអញ្ជើញជាអធិបតីក្នុងពិធីអភិបូជានៅសហគមន៍ និយាយភាសាអង់គ្លេសកាលពីថ្ងៃទី៦ ខែតុលា។

នេះជាលើកទី១ ក្នុងមុខងារជាអភិបាល ដែលចុះ សួរសុខទុក្ខបងប្អូនសហគមន៍និយាយអង់គ្លេស។ នោះក៏ជាពេលធ្វើការជម្រាបលាបងស្រីវីជីនណា ដែលបានបញ្ចប់បេសកកម្មនៅប្រទេសកម្ពុជា ដែល បងស្រីបានបម្រើការអស់រយៈពេល១៥ឆ្នាំមកហើយ។

បន្ទាប់ពីអភិបូជា លោកអភិបាលអូលីវីយេ ក៏ បានជូនវត្ថុអនុស្សាវរីយជូនបងស្រីវីជីនណា ធ្វើឱ្យ បងស្រីនឹកឃើញ ជានិច្ចពីប្រទេសកម្ពុជា។


Photo : Sothirith

**ប៉ែត សុធីរិទ្ធិ**

MesNovember-2010 OK.qxd 11/12/2010 2:35 PM Page 13

# ព័ត៌មានព្រះសហគមន៍កាតូលិក

## បងស្រីរីជីនណាបញ្ចប់បេសកកម្មនៅអង្គការម៉ារីណុល

កាលពីថ្ងៃទី៤ ខែវិច្ឆិកាមុននេះ បងស្រីរីជីនណាព័រតូ បានដំណើរទៅបំពេញ បេសកកម្មថ្មីរបស់បងស្រីនៅសហរដ្ឋអាមេរិក នៅទីក្រុងញូយ៉ក បន្ទាប់ពីបងស្រីបញ្ចប់នូវភារកិច្ចជួយព្រះសហគមន៍ប្រទេសកម្ពុជាអស់ពេល១៥ឆ្នាំ ។

បងស្រីបានចាប់ផ្តើមការងារជាដំបូងនៅឆ្នាំ ១៩៩៥ ព្រះវិហារព្រះកុមារយេស៊ូនៃព្រះសហគមន៍បឹងទំពុន ជាមួយនិងសកម្មភាពអប់រំ ។

បងស្រីមានប្រសាសន៍ថា អ្វីៗដែលខ្ញុំមើលឃើញ និងទទួលបានជាបទពិសោធន៍នោះគឺបើសិនយើងចេះផ្តល់ឱកាស និងទុកពេលវេលាឱ្យអ្នកតូចតាចនោះ ពួកគេនឹងមានក្តីសង្ឃឹម និងជីវិតដ៏ល្អសម្រាប់ខ្លួនគេផ្ទាល់ និងសង្គមរបស់គេផងដែរ ។ បងស្រីក៏បានផ្តល់អនុសាសន៍ថា : "ទាំងអស់គ្នាមានព្រះអំណោយទានផ្សេងៗគ្នា ។ ដូច្នេះសម្រាប់យុវជន ពួកគេគួរប្រព្រឹត្តិខ្លួនឱ្យប្រពៃ និងត្រៀមជាស្រេច សម្រាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដោយគិតថា ទាំងនេះគឺសម្រាប់ខ្ញុំគ្រួសារខ្ញុំ ព្រះសហគមន៍ខ្ញុំ និងសង្គមជាតិ ។ ដូច្នេះខ្ញុំត្រូវតែមានសេចក្តីពិត ហើយនិងភាពស្មោះត្រង់នៅក្នុងការរស់នៅ" ។

បងស្រីបន្តថា យើងអាចស្តាប់ព្រះបន្ទូលនេះបាន តាមរយៈការអាន និងស្តាប់ព្រះបន្ទូលព្រះអង្គ និងទី២ គឺការមើលឃើញនូវទង្វើ របស់ខ្លួនរបស់អ្នកផង ដែលពោរពេញដោយក្តីស្រឡាញ់ មេត្តាករុណាសប្បុរស និងការយល់ទុក្ខធុរៈគ្នា ។ នេះនឹងនាំឱ្យយល់សេចក្តីពិតពីព្រះជាម្ចាស់ ។

សម្រាប់ភារកិច្ចថ្មីដែលរូបបងស្រី និងទទួល


Photo : Sokhorn

នោះ គឺបងស្រីនឹងធ្វើការងារនាផ្នែកគណនេយ្យរបស់អង្គការម៉ារីណុលនៅទីក្រុងញូយ៉ក ។

ក្នុងពេលទន្ទឹមគ្នានេះ អង្គការម៉ារីណុលបានចាត់តាំងបងស្រីឡូសី អារ៉េជាអ្នកតំណាងរបស់អង្គការម៉ារីណុលនៅប្រទេសកម្ពុជា គិតចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ ក្នុងអំឡុងពេល ៣ ឆ្នាំ ហើយបងស្រីនិងនៅបន្តការងាររបស់ខ្លួនជាសាស្ត្រាចារ្យនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

## លោកបូជាចារ្យប្រ៊ុយណូ កូសម៍ ទទួលមុខងារថ្មី

លោកឪពុកប្រ៊ុយណូកូសម៍ ត្រូវបានប្រគល់មុខងារថ្មីជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍ផ្សារតូច និងមណ្ឌលសកម្មភាពភ្នំពេញ កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១០ កន្លងទៅ ។ លោកបូជាចារ្យប្រ៊ុយណូ បានធ្វើការនៅទេវវិទ្យាល័យកម្ពុជាជាង ១០ឆ្នាំ មកហើយ ។

ពិធីទទួលស្វាគមន៍ បានប្រព្រឹត្តិទៅក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ កាលពីថ្ងៃទី១៧ ខែតុលា មុននេះ នៅព្រះសហគមន៍ផ្សារតូច ។

មណ្ឌលសកម្មភាពភ្នំពេញ មានព្រះសហគមន៍កាតូលិកផ្សារតូច ពោធំ ក្តីកណ្តាល ស្វាយប៉ាក តូតាំង កងណយ ព្រែកតាទែន ដុនបូស្កូ កោះនរា និងពោធិ៍ចិនតុង ។

លោអភិបាលសុខកុមារ អូលីវីយេ បានរំឭកដល់លោកបូជាចារ្យនូវទទួលមុខងារថ្មីថា មុខងារដែលលោកទទួល គឺជាអ្នកដឹកនាំ ជាអ្នកអប់រំ ណែនាំ និងការអធិដ្ឋាន ដើម្បីឱ្យជំនឿរឹងមាំ និងស្ថិតនៅជាប់ជានិច្ចជាមួយព្រះជាម្ចាស់ ។

លោកអភិបាលបានបញ្ជាក់ថា លោកបូជាចារ្យមានតួនាទីថ្វាយអភិបូជា ប្រកាស ដំណឹងល្អ អប់រំជំនឿ ណែនាំថែបំប៉នជីវិតខាងវិញ្ញាណ និងធ្វើការដោយសហការជាមួយគ្នា ។ លោកត្រូវយកចិត្តទុកដាក់ដល់អ្នកឈឺចាប់ ទាំងផ្លូវកាយ និងផ្លូវចិត្ត ។

លោកបូជាចារ្យ ប្រ៊ុយណូ មានកំណើតនៅឆ្នាំ ១៩៦៤ នៅប្រទេសបារាំង លោកទទួលអគ្គសញ្ញាតែងតាំងបូជាចារ្យនៅឆ្នាំ១៩៦៤ ក្នុងក្រុម សាសនទូតក្រៅប្រទេស នាទីក្រុងប៉ារីស និងបានចូលមកបម្រើការនៅប្រទេសកម្ពុជា នៅឆ្នាំ១៩៩៥ ។


Photo : L. Sovanna

**លី សុវណ្ណា**

## កសិករអាស៊ីតស៊ូនឹងបញ្ហាបម្រែបម្រួលអាសកាសធាតុ

កសិករដែលមកពីទ្វីបអាស៊ីបានជួបប្រជុំគ្នាក្នុងប្រទេសកម្ពុជាដើម្បីចែករំលែកបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេក្នុងការដោះស្រាយនូវបញ្ហាបម្រែបម្រួលអាកាសធាតុ ។

សន្និសីទកសិករអាស៊ីអាគ្នេយ៍ ពីថ្ងៃទី១១ ដល់ថ្ងៃ១៧ ខែតុលា នៅក្នុងទីក្រុងភ្នំពេញនេះត្រូវបានរៀបចំដោយអង្គការការីតាសកម្ពុជា និងសហការជាមួយអង្គការ ស៊ី អរ អេសកម្ពុជា ការីតាសអាស៊ី និងក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនៃរាជរដ្ឋាភិបាល ។

លោកហ្គាប្រៀល បារ៉យ ប្រធានអង្គការការីតាសអាស៊ី មានប្រសាសន៍ថា គោលលបំណងនៃសន្និសីទនេះ គឺសម្រាប់កសិករ និងមន្ត្រីគ្រប់គ្រងកម្មវិធីធ្វើការផ្លាស់ប្តូរ និងរៀនពីគ្នាទៅវិញទៅមកពីកសិកម្មសរីរាង្គ និងដើម្បីការពារសិទ្ធពួកគេទៅលើវប្បធម៌ ធនធានក្នុងស្រុក ពាណិជ្ជកម្ម និងការចិញ្ចឹមជីវិតរាល់ថ្ងៃ និងយុត្តិធម៌អាកាសធាតុ ។

ការីតាសអាស៊ី និងអតីតដៃគូអភិវឌ្ឍន៍ធនធានមនុស្សនៅអាស៊ី តែងតែរៀបចំសន្និសីទកសិករ ជារៀងរាល់ឆ្នាំតាំងពីឆ្នាំ១៩៩០ ។ ក្នុងសន្និសីទ លើកនេះ អ្នកចូលរួមទាំងអស់បានធ្វើការជាមួយកសិករកម្ពុជានៅតាមបណ្តាខេត្តផ្សេងៗ ហើយនិងផ្លាស់ប្តូរលទ្ធផលគ្នាទៅវិញទៅមកនៅក្នុងអង្គប្រជុំ ។

លោកគីម រតនា នាយកប្រតិបត្តិអង្គការការីតាសកម្ពុជា មានប្រសាសន៍ថា កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសអាស៊ីនានា ដែលងាយរងគ្រោះដោយសារបម្រែបម្រួលអាកាសធាតុ ។

**អ៊ឹម សុខន**

MesNovember-2010 OK.qxd 11/12/2010 2:36 PM Page 14

# បទយកការណ៍ព្រះសហគមន៍កាតូលិក

## បូជនីយចរណ៍លើកដំបូងបង្អស់នៃយុវជនកាតូលិកភូមិភាគភ្នំពេញ

**យឹម ម៉ារី**

លោក បូជាចារ្យ បងប្រុស បងស្រី និងយុវជនយុវនារីប្រមាណជា ១៦០នាក់ ដែលជាបូជនីយជនបានធ្វើ ដំណើរក្នុងចម្ងាយផ្លូវប្រមាណជា២១គីឡូម៉ែតដោយថ្មើរជើងចេញដំណើរពីភូមិសំព័រ ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម ទៅកាន់ភូមិថ្លា ឃុំច្រនៀង ស្រុកបារាយណ៍ ខេត្តកំពុងធំ កាលពីថ្ងៃទី៣០ វិច្ឆិកា មុននេះ។ ក្នុងពេលធ្វើដំណើរបូជនីយជនទាំងអស់ ត្រូវសូត្រផ្គាំ និងអធិដ្ឋាន។

លោកផុនសុផល អ្នកសម្រប់សម្រួលកម្មវិធីនៃការិយាល័យយុវជន និងកុមារ ប្រាប់ឱ្យដឹងថា កម្មវិធីនេះ ធ្វើក្នុងគោលបំណងសំខាន់ពីរ គឺទី១ យើងធ្វើដំណើររួមគ្នាក្នុងក្តីស្រលាញ់ និងមានទិសដៅតែមួយ។ ទី២ នេះជាឱកាសបើកឆ្នាំ២០១០-២០១១ នៃយុវជនក្រោមប្រធានបទយុវជន និងចំណេះដឹងផ្នែកសង្គមដោយយកព្រះយេស៊ូជាគំរូ។

លោកអភិបាលភូមិភាគភ្នំពេញ អូលីវីយេ បានថ្លែងថា លោកមានទូវអំណរសប្បាយ និងពេញចិត្តយ៉ាងខ្លាំងដែលក្រុមការងាររបស់ការិយាល័យយុវជន និងកុមារ បានរៀបចំកម្មវិធីបូជនីយចរណ៍ ជាលើកដំបូង នៅប្រទេសកម្ពុជា ស្របតាមប្រពៃណីសាសនាតាំងពីដើមមក។ នាឱកាសនោះ លោកអភិបាល បានប្រកាសបើកឆ្នាំយុវជន ក្រោមប្រធានបទ យុវជន និងចំណេះដឹងផ្នែកសង្គមដោយយកព្រះយេស៊ូជាគំរូ ដើម្បីឱ្យយុវជនរិះគិតពីជីវិតរបស់ខ្លួនថា អាចចូលរួមអ្វីខ្លះជាមួយនិងសកម្មភាពនៅក្នុងសង្គមក្នុងនាមព្រះជាម្ចាស់។

លោកហ្គូស្តាវូ អេទីយ៉ាន បេនីតេស បូជាចារ្យជួយសម្របសម្រួលកម្មវិធីនៃការិយាល័យយុវជន និង កុមារ មានប្រសាសន៍ថា លោកគឺពិតជាមានក្តីសោមនស្សរីករាយ និងពេញចិត្តចំពោះផ្លែផ្កា ដែលបានមកពីបូជនីយចរណ៍នេះ។ ពួកគេគឺមានទឹកមុខរីករាយ និងធ្វើដំណើរឆ្ពោះទៅទិសដៅ ដោយកាន់ព្រះឈើឆ្កាងនាំមុខក្នុងការបង្ហាញអំពីវត្តមានព្រះជាម្ចាស់ក្នុងសង្គម។ ពួកគេគឺជាសាក្សី និងជាសក្ខីភាពនៃព្រះយេស៊ូ។

យុវជនយុវនារីជាបូជនីយជន ក៏ប្រាប់ឱ្យដឹងផងដែរថា ពួកគេពិតជាមានមោទនភាព និងភាពរីករាយយ៉ាង ខ្លាំងដែលបានដើរដង្ហែជាក្បួននៃបូជនីយចរណ៍ ដែលនេះជាលើកទីមួយហើយ ដែលពួកគេអាចដើរក្នុងចម្ងាយផ្លូវឆ្ងាយយ៉ាងនេះ។ទិដ្ឋភាពបរិយាកាស ភាពនឿយហត់ ឧបសគ្គ និងការអស់កម្លាំងខ្លះៗ ពេលកំពុងដំណើរ នាំឱ្យយើងរិះគិតអំពីការរងទុក្ខលំបាករបស់ព្រះយេស៊ូដើម្បីរំដោះបាបឱ្យយើងរាល់គ្នា។ ដូច្នេះបូជនីយចរណ៍នេះមិនត្រឹមតែបានបង្ហាញពីវត្តមានព្រះយេស៊ូក្នុងសង្គម នោះទេ ប៉ុន្តែវាក៏បានផ្តល់បទពិសោធន៍ជាច្រើនដែលនាំយើងរិះគិតអំពីជីវិតរបស់យើងជាយុវជនកាតូលិកនៅក្នុងសង្គម។

ផូ វី និស្សិតទេវវិទ្យាល័យ ប្រាប់ឱ្យដឹងថា: "អ្វីដែលខ្ញុំទទួលបានពីកិច្ចបូជនីយចរណ៍នេះ គឺជាការតស៊ូ និងមានមោទនភាពក្នុងការបង្ហាញអំពីវត្តមានព្រះជាម្ចាស់ឱ្យអ្នកដទៃបានដឹង។ ពេលធ្វើដំណើរតាមផ្លូវ ពួកយើងប្រឈមនិងភាពងឿងឆ្ងល់របស់អ្នកភូមិ តែខ្ញុំជឿថា ទោះបីជាពួកគេយល់ ឬមិនយល់អំពីអ្វីដែលយើងកំពុងធ្វើ ក៏គេបានឃើញអំពីវត្តមាននៃព្រះយេស៊ូ និងទទួលបានព្រះពរពីព្រះជាម្ចាស់ត្បិតព្រះអង្គស្រលាញ់មនុស្សគ្រប់រូប"។

កញ្ញាពាង ចន្ធី មកពីព្រះសហគមន៍កោះស្លា ក៏បន្ថែមថា អ្វីៗដែលយើងស្វែងរកបានដោយលំបាកពិតជាមានន័យណាស់។ បូជនីយចរណ៍នេះបានធ្វើឱ្យខ្ញុំយល់ពីការតស៊ូ និងខិតខំប្រឹងប្រែងធ្វើសាក្សីរបស់ព្រះជាម្ចាស់ក្នុងសង្គមដោយស្តែងជាសកម្មភាពល្អៗជាគំរូ នៅក្នុងនាមយុវជនកាតូលិកដែលមានជំនឿលើព្រះជាម្ចាស់។



Photo : Mary

## ជីវិតខ្ញុំ

# ការងារដោយក្ដីស្រឡាញ់គឺប្រកាសដំណឹងល្អនៃព្រះជាម្ចាស់

**អ៊ឹម សុខន**



Photo : Sokhorn

លោកអេមីល ដេតម្ប អភិបាលព្រះសហគមន៏កាតូលិកភូមិភាគភ្នំពេញ មានកំណើត នៅប្រទេសបារាំងនៅឆ្នាំ១៩៣៥។ លោកបានទទួលអគ្គសញ្ញាជាបូជាចារ្យនៅឆ្នាំ១៩៦១។ លោកបានមកបម្រើប្រជាជនកម្ពុជាតាំងពីឆ្នាំ ១៩៦៤។

នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៧ លោកត្រូវបានតែងតាំងជាអភិបាលឧបតម្ភកនៅព្រះសហគមន៏កាតូលិកភូមិភាគ ភ្នំពេញ គឺជាជំនួយការឱ្យលោកអភិបាល អ៊ីវ រ៉ាម៉ូស។ នៅថ្ងៃ១៤ ខែមេសា នាឆ្នាំ២001 លោកបានទទួលងារជាអភិបាលពេញសិទ្ធិប្រចាំព្រះសហគមន៏កាតូលិកភូមិភាគភ្នំពេញ។

កាលពីថ្ងៃទី១ តុលា ឆ្នាំ២០១០នេះ នាម៉ោង៥រសៀល។ សម្ដេចប៉ាបបេណេឌីកទី១៦ នៃបុរីរ៉ូមបានចេញនូវសារលិខិតប្រកាសជាផ្លូវការតាមរយៈអគ្គរាជទូតរបស់សម្ដេចប៉ាបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅទីក្រុងបាំង-កកប្រទេសថៃជូនដល់លោកអភិបាល។សារលិខិតមានខ្លឹមសារថា លោកអភិបាលអេមីល ដេតម្បជាអភិបាលភូមិភាគភ្នំពេញ ត្រូវចូលនិវត្តន៍ តាមការកំណត់អាយុនៃច្បាប់ព្រះសហគមន៏កាតូលិក។ ភារកិច្ចនិងមុខងារជាអភិបាលភូមិភាគភ្នំពេញត្រូវប្រគល់ជូនលោកអភិបាលឧបតម្ភកសុខកុមារ អូលីវីយេ ជ្មិតអ៊ីស្លែរ ជាអ្នកទទួលត្រូវជាបន្ត។

លោកអភិបាលអេមីល ដេតម្ប មានប្រសាសន៏ថា នៅឆ្នាំ១០៦៥ លោកបានមកបម្រើព្រះសហគមន៏កាតូលិកនៅប្រទេសកម្ពុជា។ លុះដល់ឆ្នាំ១៩-៧៥ លោកបានវិលត្រឡប់ទៅមាតុប្រទេសខ្លួនវិញដោយសារសម័យប្រល័យពូជសាសន៏ប៉ុលពត។

នៅឆ្នាំ១៩៧៩ លោកក៏តម្រូវឱ្យទៅបម្រើការព្រះសហគមន៏កាតូលិកនៅក្នុងប្រទេសប្រេស៊ីល។ លុះដល់ឆ្នាំ១៩៨៩ លោកបានត្រឡប់មកបម្រើព្រះសហគមន៏ប្រទេសកម្ពុជាជាថ្មីម្ដងទៀត តាមរយៈអ្នកស្ម័គ្ររបស់អង្គការីតាសកម្ពុជា។

លោកអភិបាលមានប្រសាសន៏បន្តថា ការបម្រើព្រះសហគមន៏ជាការរួមចំណែកជាមួយនិងបងប្អូនប្រជាជនទាំងអស់។ យើងលើកទឹកចិត្តគ្នានិងយល់ទុក្ខធុរៈគ្នា។ លោកក៏ពោលថា: "តាមរបៀបរបស់ព្រះសហគមន៏កាតូលិក គឺយើងធ្វើការមិនមែនជារាងត្រីកោណ តែជារង្វង់មូលដែលមានក្ដីស្រលាញ់នៅខាងក្នុង នាខណៈដែលយើងម្នាក់ៗមានមុខងារដោយឡែកៗ ផ្សេងៗ ពីគ្នានៅក្នុងសង្គម"។

លោកអភិបាលបន្ថែមថា កិច្ចការដែលយើងធ្វើដោយក្ដីស្រលាញ់ ជូនចំពោះអ្នកតូចតាច គឺប្រៀបបាននឹងយើងប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់។ យើងម្នាក់ត្រូវធ្វើជាគំរូដល់ល្អដល់អស់បងប្អូន ក្នុងនាមជាបុត្រធីតារបស់ព្រះយេស៊ូដែលទ្រង់បានបូជាព្រះជន្មសម្រាប់យើង។

## ប្រតិទិនអភិបូជា

- **ភាសាខ្មែរ** : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៥រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- **Français** : 1er et 3ème Samedi du mois à 5:30pm ; 2ème et 4ème Dimanche du mois à 11:00am; à l'église de St. Joseph, #1788B, RN5, PP.
- **English** : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).

# ប្រវត្តិសាស្ត្រ

# កាតាតឺជាប្រទេសអារ៉ាប់មានសេរីភាពជាងគេក្នុងតំបន់

**ជាត សំភី**

កុលសម្ព័ន្ធចរកជនជាច្រើនក្រុម បានមកតាំងទីលំនៅ ឬនៅលើឆ្នេរដែលបង្កើតបានជាភូមិនេសាទតូចៗជាច្រើន នៅលើទឹកដីកាតា។ក្រុមកុលសម្ព័ន្ធអស់ទាំងនេះ បានប្រយុទ្ធប្រឆាំងគ្នា ដើម្បីដណ្តើមទឹកដីដែលផ្តលផលកម្រៃច្រើន។

នៅសតវត្សរ៍ទី១៧ ប្រទេសកាតាត្រូវបានកត់សម្គាល់ដោយអំពើហិង្សា ឬប្រកួតប្រជែងគ្នារវាងកុលសម្ព័ន្ធដែលចង់កាន់កាប់លើទឹកដីទាំងមូល។

ជម្លោះរវាងកុលសម្ព័ន្ធនានាបានបន្តរហូតដល់ដើមសតវត្សរ៍ទី១៩ នៅខណៈពេលដែលជនជាតិអង់គ្លេសបានសម្រេចចិត្តចូលធ្វើអន្តរាគមន៍។

សង្គ្រាមលោកលើកទី២ បានធ្វើឱ្យប៉ះពាល់ដល់ឥទ្ធពលអំណាចរបស់ចក្រភពអង់គ្លេស។ ការជំរុញឱ្យមានការដកថយចេញពីបណ្តាលរដ្ឋនៅនៅក្នុងតំបន់ឈូងសមុទ្រត្រូវបានបង្កើនល្បឿននៅអំឡុងទសវត្សរ៍ឆ្នាំ១៩៥០។

អំឡុងទសវត្សរ៍ឆ្នាំ១៩៦០ កាតា បារ៉ែន និងរដ្ឋ៧ផ្សេងៗទៀត បានបង្កើតជាសហព័ន្ធមួយ។ ប៉ុន្តែជម្លោះនៅក្នុងតំបន់នាំឱ្យកាតាប្រកាសនូវឯករាជ្យរបស់ខ្លួននៅចំពោះមុខនៃប្រទេសសម្ព័ន្ធដែលប្រែក្លាយជាសហភាពអារ៉ាបរួម។ នៅឆ្នាំ១៩៧១ កត់សម្គាល់នូវការចាប់កំណើតរបស់កាតា ជារដ្ឋអធិបតេយ្យភាព និងបានចូលជាសមាជិករបស់ អង្គការសហប្រជាជាតិ។



## ភូមិវិទ្យារបស់ប្រទេសកាតា

កាតាគឺជារដ្ឋនៅឧបទ្វីបអារ៉ាប៊ី តំបន់មជ្ឈិមបូព៌ាដែលមានផ្ទៃដី ១១៤២៧ គម$^២$។ ប្រជាជនមានចំនួន ៨៤០៩២៦ នាក់ ដែល៧៧,៥% គឺកាន់សាសនាឥស្លាម។

រដ្ឋនេះមានទីតាំងនៅជ្រោយមួយដែលមានប្រទេសអារ៉ាប៊ី សាអ៊ូឌីតនៅភាគខាងត្បូង និងឈូងសមុទ្រពែរ្ស៍នៅភាគខាងជើង។ រាជធានីរបស់កាតា គឺដូហា Doha ឬអាដដាវ៉ា Ad Dawah។ ភាសាផ្លូវការ គឺអារ៉ាប់ និងអង់គ្លេសប្រើប្រាស់ទូលំទូលាយ។ រូបិយវត្ថុ គឺរីយ៉ាល់កាតារី Riyal Qataris។

កាតាជាសមាជិកនៃអង្គការប្រទេសនាំចេញប្រេងពិភពលោក ហៅ អូពិច(OPEP)។ កាតាជាប្រទេសនាំចេញឧស្ម័នធម្មជាតិទីបីនៅលើពិភពលោក និងក្លាយជាអ្នកនាំចេញឧស្ម័នធម្មជាតិទីមួយនៅក្នុងសភាពរាវ។

នាឆ្នាំ២០០៥ ប្រទេសកាតាគឺបានដឹកនាំដោយព្រះអង្គម្ចាស់ហាម៉ាត់ ប៊ីន ខាលីហ្វា អាល់ ថានី។ ព្រះអង្គបានទម្លាក់ឪពុករបស់ខ្លួន គឺស្តេច ខាលីហ្វា ប៊ីន ហាម៉ាត់ អាល់ ថានី តាំងពីឆ្នាំ១៩៩៥។

នៅក្រោមការគ្រប់គ្រងរបស់ស្តេចហាម៉ាត់ ប៊ីន ខាលីហ្វាអាល់ ថានី ប្រទេសកាតាបានធ្វើនូវ កំណែទម្រង់សង្គមជាច្រើនដូចជាសិទ្ធស្ត្រី និងនយោបាយ។ ស្តេចថ្មីបានដឹកនាំប្រទេសប្រកាន់យកនិន្នាការសេរីច្រើនជាងឪពុករបស់ខ្លួន។ ព្រះអង្គស្ថាបនារដ្ឋធម្មនុញ្ញថ្មីសម្រាប់ប្រទេសជាតិ។ ព្រះអង្គបានបង្កើតអាល់ហ្សីរ៉ាដែលដូចជាសារព័តិមានស៊ីអ៊ិនអ៊ិនរបស់អារ៉ាប ដែលបានក៏សាងកិត្តិសព្ទជាច្រើន សម្រាប់ប្រទេសជាតិ។


Photos : DR

### នយោបាយ និងសេដ្ឋកិច្ច

រដ្ឋាភិបាលកាតាបានរក្សាការរឹតបន្តឹងមួយចំនួនលើសេរីភាពនៃការបញ្ចេញមតិ ឬក៏ចលនាដើម្បីសមភាព។ តែបើប្រៀបធៀបនឹងប្រទេសជិតខាងរបស់ខ្លួនដូចជា អារ៉ាប៊ី សាអ៊ូឌីត កាតាគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេរីភាពបំផុតនៅក្នុងតំបន់។ គ្មានគណបក្សនយោបាយណាមួយមានវត្តមាននៅក្នុងប្រទេសទេ។

រដ្ឋមន្ត្រីការបរទេស ដែលត្រូវបានសាកសួរ ជាច្រើនដងលើបញ្ហានេះបានឆ្លើយថា កាតាជាប្រទេសតូច មិនអាចផ្ទុកនូវគណបក្សនយោបាយច្រើនទេ។

មុនពេលដែលគេរកឃើញប្រេងកាត កាតាជាតំបន់នេសាទយ៉ាងសំខាន់ និងជាកន្លែងធ្វើវប្បកម្មគុជសមុទ្រ។ ការរកឃើញប្រេងកាត នៅទសវត្សឆ្នាំ១៩៤០ដែលបានផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ប្រទេសជាតិទាំងស្រុង។ ប្រេងកាតតំណាងឱ្យ៨០ភាគរយនៃចំណូលរបស់ប្រទេសកាតា។

ក្រៅអំពីរ៉ែ ប្រេងកាត និងឧស្ម័ន កសិកម្ម ការចិញ្ចឹមសត្វ ការនេសាទ ជាធនធានប្រពៃណី របស់ប្រជាជន បានដំណើរការតាមរយៈកសិដ្ឋាន ដែលមានពិសោធន៍របស់រដ្ឋ។ ការនេសាទអាចបំពេញបាននូវតម្រូវការ ៩០% នៅក្នុងប្រទេស។

ប្រទេសកាតាបានឈានទៅដល់កម្រិតជីវភាពខ្ពង់ខ្ពស់ ដោយរដ្ឋផ្តល់ឱ្យប្រជាពលរដ្ឋរបស់ខ្លួន នូវគ្រប់សេវាកម្មសង្គមសមរម្យ។

កាតាអ៊ែរវ៉េជាក្រុមហ៊ុនអាកាសចរណ៍មួយនៅក្នុងចំណោមក្រុមហ៊ុនអាកាសចរណ៍ទាំងបួន របស់ពិភពលោក ដែលចាត់ថ្នាក់កម្រិតផ្កាយប្រាំ។

MesNovember-2010 OK.qxd 11/12/2010 2:36 PM Page 17






Photo : Rithy

# កម្ពុជាធ្វើជាម្ចាស់ផ្ទះ មហោស្រប ភាពយន្តអន្តរជាតិ ជាលើកទី១

**ខាន់ ភីរម្យ**

ខ្សែភាពយន្តចំនួន១២០រឿង មកពី២៨ ប្រទេសបានត្រូវគេយកមកបញ្ចាំងក្នុងរយៈពេល ៤ថ្ងៃ នៅមហោស្របភាពយន្តអន្តរជាតិដែលគេរៀបចំធ្វើឡើងជាលើកទីមួយ នៅព្រះរាជាណាចក្រកម្ពុជា។

មហោស្របភាពយន្តអន្តរជាតិនេះ ត្រូវបានរៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយសហការជាមួយនិងអង្គការយូណេស្កូ ព្រមទាំងគណៈកម្មាធិការភាពយន្តកម្ពុជាផងដែរ។

ភាពយន្តជាច្រើនត្រូវបានចាក់បញ្ចាំងពីថ្ងៃទី២០ ហើយបានបញ្ចប់នៅថ្ងៃទី២៤ ខែតុលា កន្លងទៅនេះ។

លោកឃឹម សារិទ្ធ រដ្ឋលេខាធិការ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានប្រសាសន៍ថា នេះគឺជាមហោស្របភាពយន្តអន្តរជាតិលើកទីមួយ ដែលកម្ពុជា បានធ្វើជាម្ចាស់ផ្ទះ។ លោកបន្តថាគោលបំណងនៃការរៀបចំមហោស្របនេះឡើងគឺដើម្បីធ្វើការលើកកម្ពស់ខាងផ្នែកគុណភាពរបស់វិស័យឧស្សាហកម្មភាពយន្តនៅក្នុងប្រទេសកម្ពុជា និងម្យ៉ាងទៀតក៏ដើម្បីធ្វើការចែករំលែកនូវបទពិសោធន៍បច្ចេកទេសរវាងគ្នានិងគ្នា ក្នុងការផលិតខ្សែភាពយន្ត។

លោកឃឹម សារិទ្ធ បន្តថា មហោស្របនេះក៏នឹងជួយដល់ផលិតករ និងអ្នកថតខ្សែភាពយន្តនៅក្នុងប្រទេសកម្ពុជា គឺអាចដកស្រង់បច្ចេកទេសដើម្បីអភិវឌ្ឍការថតខ្សែភាពយន្តក្នុងរូបភាពផលិតធ្វើជាឧស្សាហកម្ម ក៏ដូចជាដើម្បីផលិតកម្មខ្សែភាពយន្តរបស់ខ្លួន។ សកម្មភាពទាំងនេះអាចចូលរួមលើកស្ទួយវិស័យភាពយន្តនៅកម្ពុជាបានយ៉ាងច្រើន។ ហើយទស្សនីភាពនេះ ក៏អាចជាការបញ្ជាក់ប្រាប់ និងផ្តល់សញ្ញាទៅដល់បណ្តាភ្ញៀវទេសចរណ៍ទាំងអស់ថាកម្ពុជាគឺជា ប្រទេសមួយ ដែលមានវប្បធម៌សម្បូរបែបដែលមិនមែនមានត្រឹមតែប្រវត្តិសាស្ត្រ និងបេតិកភណ្ឌនោះទេ។

បណ្តាប្រទេសដែលបានយកភាពយន្តមកចូលរួមនៅក្នុងមហោស្របនេះដែរ រួមមាន ប្រទេសកម្ពុជាជាម្ចាស់ផ្ទះ អូស្ត្រាលី ចិន ប្រេស៊ីល បារាំង ឥណ្ឌា កូរ៉េខាងត្បូង ម៉ាឡេស៊ី ម៉ិកស៊ិកូ ហ្វីលីពីន និងអាម៉េរិក ជាដើម។ចំណែកប្រភេទខ្សែភាពយន្តដែលគេបានយកមកបញ្ចាំងនោះ គឺរួមមានខ្សែភាពយន្តបុរាណ និងភាពយន្តសម័យទំនើបរបស់កម្ពុជា ខ្សែភាពយន្តអំពីយុវជន ព្រមទាំងរឿងទាំងឡាយដែលគេធ្វើចាក់ផ្សាយតាមទូរទស្សន៍ និងវីដេអូតន្ត្រីជាដើម។

## អំណាន

### ភូមិសាស្ត្រនយោបាយ ប្រទេសចិន




ស្នាដៃនេះគឺជាការវិភាគពីបច្ចុប្បន្នភាពដ៏ក្តៅគគុក និងពិពណ៌នាអំពីមហិច្ឆតាដ៏ពិតប្រាកដរបស់ចិន ទំនាក់ទំនងរវាងចិន ជាមួយបណ្តាប្រទេសជិតខាង និងការប្រឈមមុខដាក់គ្នារវាងចិន និងអាម៉េរិក។ ម្យ៉ាងទៀតឯកសារនេះជួយបើកចំហចិត្តគំនិតប្រជាជនខ្មែរឱ្យទំលំទូលាយ និងចូលចិត្តអាន ពីព្រោះនេះមិនមែនមានតែ "បញ្ហាខ្មែរ វៀតណាម ឬមួយថៃ"ទេ ជាពិសេសអ្នកអាននឹងបានដឹងទៀតថា ក្នុងក្របខណ្ឌទំនាក់ទំនងអន្តរជាតិ គឺគ្មានទេមិត្ត គ្មានទេសត្រូវ គឺមានតែផលប្រយោជន៍មួយគត់។

សៀវភៅនេះវិភាគអំពីភូមិសាស្ត្រនយោបាយសម្រាប់ជួយផ្តល់ចំណេះដឹងដល់និស្សិតខ្មែរដែលគ្មានលទ្ធភាពអានឯកសារជាភាសាបរទេសដើម្បីឱ្យពួកគេយល់ដឹងអំពីគន្លឹះសំខាន់ៗនៃទំនាក់ទំនងអន្តរជាតិ និងអំពីយន្តការ ដ៏សែនស្មុគស្មាញនៃភូមិសាស្ត្រនយោបាយរបស់ប្រទេសមហាអំណាចនៅលើពិភពលោក។

សៀវភៅនេះនិពន្ធដោយហ្សង់ហ្វ្រង់ស័រ តាន់ ។

### ព្រះករុណាព្រះស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជាធិបតី និងព្រះរាជដំណើរទៅបារាំង



នេះជាឯកសារដែលនិយាយអំពីទស្សនកិច្ចជាផ្លូវការ រយៈពេល ៤០ថ្ងៃរបស់ព្រះបាទស៊ីសុវត្ថិនៅប្រទេសបារាំង។ ព្រះអង្គបានធ្វើឱ្យប្រជាជនបារាំងរំភើបចិត្តខុសអំពីធម្មតា ដោយសារទ្រង់បានប្រទានព្រះរាជទ្រព្យ ៥០០ហ្វ្រង់មាសដើម្បីជួយដល់កម្មករអណ្តូងរ៉ែ ដែលជួបគ្រោះមហន្តរាយនៅឯតំបន់គូរៀ ប្រទេសបារាំង។ ម្យ៉ាងទៀតនេះគឺជាសក្ខីភាពនៃការការរាប់អាន និងទំនាក់ទំនង រវាងប្រទេសកម្ពុជា និងប្រទេសបារាំងនៅក្នុងសម័យអាណាព្យាបាល ទោះបីជាប្រទេស ទាំងពីរធ្លាប់មានភាពចម្រូងចម្រាសខ្លះៗ ក្នុងប្រវត្តិសាស្ត្រក៏ដោយ។

សៀវភៅនេះងាយស្រួលអាន និងស្រួលយល់ ទោះបីជាសរសេរក្នុងទម្រង់អក្ខរាវិរុទ្ធចាស់ និងសម្បូរទៅដោយពាក្យរាជស័ព្ទក្តី។ នេះជាឯកសារដ៏កម្រនិងសំខាន់ណាស់សម្រាប់អ្នកសិក្សាស្រាវជ្រាវខាងប្រវត្តិសាស្ត្រ។

សៀវភៅនេះនិពន្ធដោយឧកញ៉ា វាំង ជួន។

**ហេង ដារី**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



**ខែវិច្ឆិកា ដោយលោកបូជាចារ្យអ៊ុន សួន នៅព្រះសហគមន៍កាតូលិកតំបន់កំពត**

**អាទិត្យទី៣២ រដូវធម្មតា (ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១០)** *(លូកា ២០ ២៧ ៣៨)*

ព្រះបន្ទូលថ្ងៃអាទិត្យនេះជួយបំភ្លឺយើងអំពីជីវិតក្រោយសេចក្ដីស្លាប់។

ព្រះជាម្ចាស់ពុំមែនជាព្រះរបស់មនុស្សស្លាប់ទេ គឺជាព្រះរបស់មនុស្សដែលមានជីវិតរស់នៅ។ តាមអត្ថបទគម្ពីរព្រះជាម្ចាស់ជាប្រភពនៃជីវិត។ ព្រះអង្គមានព្រះបំណងមិនចង់ឱ្យមនុស្សស្លាប់ ឱ្យមនុស្សយើងរស់ជានិច្ច។

ព្រះយេស៊ូមានព្រះបន្ទូលប្រាប់យើងឱ្យដឹងជ្រាបអំពីការផុតពីជាតិនេះទៅ យើងនៅតែមានជីវិតតទៅមុខទៀត តែតាមរបៀបថ្មី...។ ព្រះអង្គបញ្ជាក់សេចក្ដីពីរយ៉ាងច្បាស់លាស់ឱ្យយើងជឿសង្ឃឹមថា: ប្រការទី១ គឺមនុស្សស្លាប់ទាំងអស់នឹងរស់ឡើងវិញ ព្រោះព្រះជាម្ចាស់មិនមែនព្រះរបស់មនុស្សស្លាប់ទេ គឺជាព្រះដែលមានជីវិតរស់នៅ។ ប្រការទី២ ជីវិតរបស់អ្នកដែលបានរស់ឡើងវិញគឺខុសពីជីវិតរបស់យើងរស់នៅសព្វថ្ងៃនេះ គឺមិនស្លាប់ទៀតទេ ហើយក៏មិនវិលក្នុងវាលវដ្ដសង្សារទៀតដែរ តែគេរស់នៅក្នុងមហាគ្រួសារជាមួយបងប្អូនឯទៀត ដែលជាប្រជាជនរបស់ព្រះជាម្ចាស់។

**សេចក្ដីខាងលើនេះនាំឱ្យយើងជឿថា មនុស្សស្លាប់នឹងរស់ឡើងវិញ ព្រោះព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។**

**អាទិត្យទី៣៣ រដូវធម្មតា (ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១០)** *(លូកា ២១ ៥ ១៩)*

ថ្ងៃអាទិត្យនេះ និងថ្ងៃអាទិត្យបន្ទាប់ទៀត ណែនាំយើងឱ្យរិះគិតអំពីអវសានកាលនៃពិភពលោក។

តាំងពីដើមរៀងមក មនុស្សយើងចេះតែខ្លាចស្លាប់ ឬ"ភ្លើងឆេះកល្ប"។ សព្វថ្ងៃនេះនៅតែមានអ្នកដើរឃោសនាអំពីអវសានកាលនៃពិភពលោកនេះដើម្បីបំភ័យអ្នកដទៃទៀត។ ព្រះយេស៊ូមានព្រះបន្ទូលប្រាប់យើងថា ចូរប្រុងប្រយ័ត្នកុំឱ្យមាននរណាម្នាក់បញ្ឆោតអ្នករាល់គ្នាឱ្យវង្វេងបានឡើយ។ ចំពោះយើងជាគ្រីស្ដបរិស័ទវិញ យើងមិនតក់ស្លុត ព្រោះយើងជឿថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយព្រះអង្គជាម្ចាស់នៃជីវិតរបស់មនុស្សគ្រប់រូប។

តាំងពីដើមរៀងមកតែងតែមានកើតអព្ភូតហេតុផ្សេងៗ ដូចជារញ្ជួយព្រះធរណី ទុរភិក្ស និងមានសង្គ្រាមជា ដើម-ល-។ ការណ៍ទាំងនេះកើតពីធម្មជាតិ ឬមនុស្សប្រព្រឹត្តផ្ដេសផ្ដាស មិនមែនជាទីសម្គាល់អវសាននៃពិភពលោកទេ។ ផ្ទុយទៅវិញ យើងត្រូវជួយពន្លត់ភ្លើងសង្គ្រាមបំបាត់ ទុរភិក្ស និងជួយអ្នករងគ្រោះតាមសមត្ថភាពរៀងៗខ្លួន។ **"អ្នករាល់គ្នានឹងបានរួចជីវិតដោយមានចិត្តស៊ូទ្រាំអត់ធ្មត់ជានិច្ច"។ តើបងប្អូនចង់ទទួលការសង្គ្រោះពីព្រះជាម្ចាស់ឬទេ ?**

**បុណ្យគោរពព្រះគ្រីស្តក្នុងឋានៈជាព្រះមហាក្សត្រនៃពិភពលោក (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១០)** *(លូកា ២៣ ៣៥ ៤៣)*

តាមធម្មតា កាលណាយើងនិយាយអំពីស្ដេច យើងតែងតែនឹកឃើញលទ្ធិផ្ដាច់ការ ឬនឹកឃើញអំណាច។ តែព្រះយេស៊ូទ្រង់បានបង្ហាញរបៀបព្រះអង្គត្រួតត្រាមនុស្សលោក គឺទ្រង់បានបម្រើអ្នកស្រុករហូតដល់បូជាព្រះជន្ម។

ព្រះយេស៊ូពុំមែនជាស្ដេច ដូចស្ដេចឯទៀតនៅក្នុងពិភពលោកនេះទេ។ ព្រះអង្គជាព្រះមហាក្សត្រព្រោះព្រះអង្គ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយសោយទីវង្គត់ និងមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូប្រទានព្រះជន្មផ្ទាល់ ឱ្យអស់អ្នកដែលជឿសង្ឃឹមលើព្រះអង្គ គឺនាំយើងឱ្យចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ដូចអ្នកទោស ២នាក់ ដែលបានជាប់នៅលើឈើឆ្កាងជាមួយព្រះអង្គ។ ចូលបងប្អូនស្ងិងស្ងាធិ៍ និងរិះគិតអំពីឋានៈរបស់ព្រះយេស៊ូជាស្ដេចរបស់យើង។

**យើងខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីឱ្យព្រះរាជ្យជាម្ចាស់ឆាប់យាងមកដល់ ?**

**អាទិត្យទី១ ក្នុងរដូវរង់ចាំ (ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១០)**

បងប្អូនជាទីស្រលាញ់! ក្នុងឱកាសរដូវរង់ចាំព្រះសហគមន៍ចូលក្នុងឆ្នាំថ្មីឆ្នាំ"ក"។ ព្រះសហគមន៍បានរៀបចំ និងដាស់តឿនឱ្យគ្រីស្ដបរិស័ទរិះគិតស្ងិងស្ងាធិ៍ និងឱ្យប្រុងស្មារតីរង់ចាំព្រះគ្រីស្ដជានិច្ច។ ព្រះជាម្ចាស់បង្រៀនតាមគម្ពីរសម្ព័ន្ធមេត្រីចាស់ និងថ្មី គឺកុំឱ្យយើងឆ្លកវង្វេង នឹងការស៊ីផឹក និងអារម្មណ៍ហួសហេតុពេក។

ព្រះយេស៊ូបានលើកយកឧទាហរណ៍មួយដើម្បីរំលឹកដាស់តឿនយើងឱ្យប្រុងប្រយ័ត្នខ្លួន "ប្រសិនបើម្ចាស់ផ្ទះដឹងថា ចោរចូលមកប្លន់ថ្មើរណា? គាត់នឹងត្រៀមខ្លួន។ នេះដូចយើងត្រៀមខ្លួនទទួលបុត្រមនុស្សយាងមកថ្ងៃចុងក្រោយ។

ខ្ញុំធ្លាប់សួរទៅអ្នកជំងឺម្នាក់ ដែលមានជំងឺមហារីកថា ខ្លាចស្លាប់ឬទេ ? គេបានសម្លឹងមើលមកមុខខ្ញុំ ស្ងៀមស្ងាត់ ហើយឆ្លើយតបមកខ្ញុំថា មិនខ្លាចស្លាប់ទេ..."។ ពេលណាម្ដាយរបស់ព្រះជាម្ចាស់មកទទួលខ្ញុំក៏បាន។ ខ្ញុំបានត្រៀមជាស្រេចហើយ"។ **តើសព្វខ្ញុំធ្វើអ្វីដើម្បីបង្ហាញឱ្យដឹងថា ខ្ញុំរង់ចាំទទួលព្រះជាម្ចាស់ ?**

## កំណាព្យ

### ការព្យាបាលចិត្តរបួសតាំងពីកុមារវ័យ *(ពាក្យប្រាំពីរ)*

១-ថ្ងៃ ២០ មិថុនា បានចារចែង ពាក្យពិតឥតក្លែងតែងអក្ខរា
លោកពុកហ្សេរ៉ាល់បូជាចារ្យ លោកបើកសិក្ខាប្រាថ្នាប៉ង។
២-យើងគ្រប់គ្នាបានស្វែងយល់ សិក្ខាក្រេបផលនូវបំណង
មានអត្ថន័យច្បាស់ជាក់ឥតហ?ង ចំណេះដឹងផងគ្រប់អង្គា។
៣-ចូលរួមបុគ្គលិកទាំងប្រុសស្រី សង្គមកិច្ចក្ដីយ៉ាងសោកា
មានស្រីមានស្រីមានចម្រុះគ្នា រួមគ្រូម្នាក់ជានាយកសាលា។
៤-គាត់ជាលោកគ្រូមើលខុសត្រូវ គ្រប់គ្រងតម្រូវជនពិការ
គាត់បានចូលខ្លួនរួមសិក្សា បងស្រីផងណាដោយរីករាយ។
៥-រួមមានសមាគមភូមិឃុំផង នារីប្អូនបងប៉ងគ្រប់កាយ
អ្នកខ្លះភូមិជិតខ្លះភូមិឆ្ងាយ រីកចិត្តឥតណាយស្ដាយចំណេះ។
៦-ខិតខំសិក្សាគ្រប់វិជ្ជា រៀងរាល់វេលាដ៏វិសេស
កត់ត្រាមេរៀនជាតម្រេះ ចងចាំចំណេះចេះបន្ត។
៧-ដល់ម៉ោងកំណត់គត់ប្រាំបី សិក្ខាប្រុសស្រីចាកចូលចរ
ត្រៀមខ្លួនរួសរាន់ទាន់ព្រឹកល្អ អង្គុយបន្តព័ទ្ធជាវង់។
៨-សិក្ខាបើកថ្មីស្ដីពព្រាយ ទឹកមុខឡំលាយភក្ដិផូរផង់
លើកដៃព្រមគ្នាប្រគុំផ្ទង់ ជម្រាបសួរត្រង់ទៅលោកពុក។
៩-លោកកាត់ពីឆ្ងាយកាយនឿយហត់ តស៊ូអត់ធ្មត់ផុតបើទុក្ខ
មិនតំអូញត្អូញថាចុក ឈឺក្បាលវិលមុខរុកគួនកាយ។
១០-នៅតែភក្ដិស្រស់ញញឹម រីករាយប៉ប្រឹមយ៉ាងសប្បាយ
ពន្យល់ណែនាំគ្រប់ៗកាយ ពាក្យពេជន៏ក្បោះក្បាយនៃមេរៀន។

*តលេខក្រោយ...*

**និពន្ធដោយអ្នកស្រីខុង ណារី**

MesNovember-2010 OK.qxd 11/12/2010 2:36 PM Page 19



# ព្រឹត្តិការណ៍កំណត់សម្គាល់វត្តមានក្រុមបងស្រីសម្ងាត់នៅកម្ពុជា

**លី សុវណ្ណា**

*ក្រុមបងស្រីសម្ងាត់ចាប់ផ្ដើមសកម្មភាពម្ដងទៀតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។ ទាំងនេះគឺជាប្រវត្តិ និងព្រឹត្តិការណ៍របស់ព្រះសហគមន៍នៅកម្ពុជា ។*



ពិធីសម្ពោធអារាមរបស់ក្រុមបងស្រីសម្ងាត់នៅរាជធានីភ្នំពេញ



ការដង្ហែក្បួននៅក្នុងពិធីបុណ្យរំឭកដល់សន្តប្រ្វង់ស៊ីស្កូដែលរៀបចំនៅព្រះសហគមន៍កាតូលិកកោះរកា ភូមិភាគកំពង់ចាម



លោកអភិបាលសុខកុមារ អូលីវីយេ ផ្មឹតអឺស្ល៊ែរបញ្ចុះអធិធាតុសន្តិតេរេសានៅក្នុងអាសនៈនៃអារាមថ្មី



លោកអភិបាលអូលីវីយេ ផ្មឹតអឺស្ល៊ែរលាបប្រេងលើសរសរនៃព្រះវិហារថ្មី



លោកអភិបាល អូលីវីយេ ផ្មឹតអឺស្ល៊ែរ ថតរូបអនុស្សាវរីយ៍ជាមួយក្រុមបងស្រីសម្ងាត់ក្នុងពិធីសម្ពោធព្រះវិហារថ្មី កាលពីថ្ងៃទី២៨ ខែតុលាមុននេះ។



បងស្រីអាតនៃអង្គការជេអេសទៅព្យាបាលជំងឺនៅបារាំង

MesNovember-2010 OK.qxd 11/12/2010 2:37 PM Page 20

## ព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញ

លេខ : ១៤/២០១០ — អភ

**សូមក្រាបបង្គំទូលថ្វាយ ព្រះពរសព្វសាធុការ**

**ថ្វាយព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

******

ទូលព្រះបង្គំយើងខ្ញុំ ជាអភិបាល បូជាចារ្យ បព្វជិត បព្វជិតា រួមជាមួយគ្រីស្តបរិស័ទ នៃព្រះសហគមន៍កាតូលិក ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា មានសេចក្តីសោមនស្សរីករាយ

**សូមក្រាបបង្គំទូលថ្វាយព្រះពរសព្វសារធុការ**

**ក្នុងព្រះរាជពិធីរាជាភិសេកគម្រប់ ៦ ព្រះវស្សា**

**ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

ទូលបង្គំយើងខ្ញុំទាំងអស់គ្នាសូមអធិដ្ឋានទូល អង្វរព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ សូមទ្រង់ព្រះមេត្តាប្រសិទ្ធពរជ័យបវរមហាប្រសើរ

**ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ឆ្លៀតក្នុងឱកាសដ៏បវរមហានិទ្ទិឫទ្ធិនេះ ទូលបង្គំជាខ្ញុំ សូមថ្លែងអំណរព្រះគុណ ចំពោះព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ដែលបានផ្តល់សញ្ញាត្តិខ្មែរ តាមសញ្ញាតូបនីយកម្មដល់រូបខ្ញុំព្រះករុណា**

សូមព្រះករុណា ព្រមទាំងព្រះរាជវង្សានុវង្ស សូមបានប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់លើរាជបល្ល័ង្ក ជាម្លប់ដ៏ត្រជាក់ត្រជុំ សុខក្សេមក្សាន្ត ចម្រុងចម្រើនរុងរឿង ដល់ប្រជានុរាស្ត្ររបស់ព្រះអង្គ ជានិច្ចនិរន្តរ៍ តរៀងទៅ។

សូម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់ និងយ៉ាងជ្រាលជ្រៅបំផុតពីព្រះសហគមន៍កាតូលិកកម្ពុជា។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០

**សុខកុមារ អូលីវីយេ ជ្មិតអ៊ីស្លែរ**
**អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ**

## វិទ្យុវ៉េរីតាស់អាស៊ី (RVA)

## ផ្នែកភាសាខ្មែរផ្សាយរយៈពេល ៥៧នាទី

## ជារៀងរាល់ថ្ងៃតាមរយៈ រលកធាតុអាកាសខ្លី

## (Short Wave = sw) គឺ :

- ពេលព្រឹក ពីម៉ោង ៨:៣០នាទី ដល់ម៉ោង ៨:៥៧នាទី ផ្សាយក្នុងរលកធាតុអាកាស ១៥២៨០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ១៩,៦៣ម៉ែត្រ។
- ពេលរសៀល ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុងរលកធាតុអាកាស ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ម៉ែត្រ។

ស្តាប់វិទ្យុវ៉េរីតាស់ អាស៊ី (RVA) លោកអ្នកនឹងទទួលបានចំណេះដឹង អំពីជីវិត និងសង្គម និងព័ត៌មាននានាពីព្រះ សហគមន៍កាតូលិកនៅកម្ពុជា។

## ការងារប្រចាំខែ

- ថ្ងៃ២-៥ វិច្ឆិកា : ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានរៀបចំប្រជុំប្រចាំឆ្នាំរបស់ខ្លួនលើកទី១០ ដែលមានការអញ្ជើញចូលរួមពីសំណាក់លោកអភិបាល លោកបូជាចារ្យ បងប្រុស បងស្រី គណៈកម្មការទាំងអស់ប្រចាំភូមិភាគ និងអង្គការមួយចំនួនទៀត ដូចជា ការីតាស មនុស្សលោកថ្មី JS និង JLMM។ អ្នកចូលរួមសរុបមានប្រមាណ ៨០នាក់ នៅព្រះសហគមន៍ខេត្តសៀមរាប។
- ថ្ងៃ៣-៤ វិច្ឆិកា : សម្ពោធព្រះវិហារថ្មី នៅខេត្តស្ទឹងត្រែង និងខេត្តរតនគីរី។
- ថ្ងៃ៦-៧ វិច្ឆិកា : លោកអភិបាលសុខកុមារ អូលីវីយេ ជ្មិតអ៊ីស្លែរ ចុះសាកសួរសុខទុក្ខគ្រីស្តបរិស័ទ និងពិនិត្យមើលការងារនៅព្រះសហគមន៍តំបន់កំពត រួមមានព្រះសហគមន៍ជុំគីរី កោះស្លា ត្រពាំងរពៅ និងព្រែកប្រស់។
- ថ្ងៃ៧ វិច្ឆិកា : ព្រះវិហារព្រះកុមារយេស៊ូនៃព្រះសហគមន៍កាតូលិកបឹងទំពុន ភ្នំពេញមានរៀបចំពិធីចែកព្រះកាយតាមផ្ទះដល់អ្នកជំងឺ។
- ថ្ងៃ១០ វិច្ឆិកា : លោកអភិបាលសុខកុមារ អូលីវីយេ ជ្មិតអ៊ីស្លែរ និងលោកបូជាចារ្យក្នុងភូមិភាគភ្នំពេញទាំងអស់ រួមគ្នាថ្វាយអភិបូជា នៅព្រះវិហារបឹងទំពុន។
- ថ្ងៃ១៣ វិច្ឆិកា : ពិធីផ្ទេរតំណែងអភិបាលពេញសិទ្ធដល់លោកអភិបាលសុខកុមារ អូលីវីយេ ជ្មិតអ៊ីស្លែរ នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច ទីក្រុងភ្នំពេញ។
- ថ្ងៃ១៩-២៤ វិច្ឆិកា : លោកឪពុកអាល់ប៊ែតូនៃព្រះសហគមន៍ភូមិភាគកំពង់ចាម ដឹកនាំនិស្សិតទេវវិទ្យាល័យធ្វើពិធីសំណាក់ធម៌ នៅអង្គការជេអេស ខេត្តសៀមរាប ដែលមានអ្នកចូលរួមប្រមាណជា ១០នាក់។
- ថ្ងៃ២១ វិច្ឆិកា ដល់ថ្ងៃ០១ ធ្នូ : យុវជនសិង្ហបុរី ២៣នាក់ ស្ម័គ្រចិត្តជួយ សាលាមត្តេយ្យនៅព្រះសហគមន៍តំបន់កំពត។
- ថ្ងៃ២៧-២៨ វិច្ឆិកា : កម្មវិធីអេម៉ាណូអែលស្តីអំពីការត្រាស់ហៅ ដែលប្រព្រឹត្តិទៅនៅទេវវិទ្យាល័យយ៉ូហាន ម៉ារី វីយ៉ាណេ និងនិវេសនដ្ឋានរបស់លោកអភិបាល ដែលនឹងមានអ្នកចូលរួមប្រមាណ ២០នាក់។
- ថ្ងៃទី៣០ វិច្ឆិកា : លោកអភិបាលសុខកុមារ អូលីវីយេ ជ្មិតអ៊ីស្លែរ ថ្វាយអភិបូជា និងធ្វើសន្និសីទនៅទេវវិទ្យាល័យ "អំពីរដូវរង់ចាំ"។